**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economic**


## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ

ស្រាវជ្រាវចាប់ពីថ្ងៃ ០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា យោ វណ្ណារី**

**កញ្ញា លេខ អ៊ីវហួ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយបណ្ឌិត **ព្រុំ រិទ្ធី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **យោ វណ្ណារី** និងនាងខ្ញុំឈ្មោះ **លេខ អ៊ីវហួ** ( ក្រុម L4A1 ) ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២៣ ។

## នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

**លោកឪពុក** និង**អ្នកម្តាយ**ជាទីគោរព ដែលមាននូវឧបការគុណដ៏ឧត្តុង្គឧត្តម និងធំធេងបំផុតគ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណដោយបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូនតាំងពីតូចរហូតដល់ធំ ហើយលោកទាំងពីរបានអប់រំ ណែនាំ និងទូន្មានប្រៀនប្រដៅឱ្យកូនចេះដឹងខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម។ ក្រៅពីនេះលោកទាំងពីរក៏បានជំរុញទឹកចិត្តឱ្យកូនខិតខំសិក្សារៀនសូត្រដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូនគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារៈ រហូតដល់កូនរៀនចប់ដោយជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រងជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឱ្យទទួលបាននូវចំណេះដឹងយ៉ាងច្រើនកន្លងមកនេះ។

**លោកសាស្ត្រាចារ្យជំនួយបណ្ឌិត ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំដោយលោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយពន្យល់ណែនាំ ផ្តល់មតិយោបល់ល្អៗ និងផ្តល់ឯកសារមួយចំនួន ព្រមទាំងជួយកែតម្រូវយ៉ាងយកចិត្តទុកដាក់បំផុតរហូតបានធ្វើឱ្យសារណាមួយនេះបានលេចចេញជារូបរាង។

ជាចុងបញ្ចប់នាងខ្ញុំទាំងពីរ សូមសម្តែងនូវសេចក្តីគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជាពិសេសសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិនៅក្នុងលោកទាំងឡាយ សូមតាមជួយថែរក្សាលោកអ្នកមានគុណទាំងឡាយឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុភមង្គល និងជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ក្រោយពីបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក នាងខ្ញុំទាំងពីរនាក់បានសិក្សាស្រាវជ្រាវលើមុខវិជ្ជាជាច្រើន ទាំងផ្នែកឯកជន និងសាធារណៈ។ ដើម្បីស្របទៅតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ នាងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តសរសេរសារណាបញ្ចប់ការសិក្សា ដោយបានជ្រើសរើសយកប្រធានបទមួយអំពី **ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ** នេះដោយយោងទៅតាមច្បាប់ ការសិក្សាកន្លងមក និងសាស្ត្រាចារ្យដែលបានចូលរួមផ្តល់ជាយោបល់ល្អៗសម្រាប់នាងខ្ញុំទាំងពីរនាក់ដើម្បីឱ្យលេចចេញជាស្នាដៃឡើង ទុកជាឯកសារមួយដែលមានសារៈសំខាន់ និងអត្ថប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយៗអាចយកទៅសិក្សារៀនសូត្រនាថ្ងៃអនាគត ទោះបីជាមានគុណប្រយោជន៍តិចក្តី ច្រើនក្តី។

ស្នាដៃមួយនេះជាស្នាដៃដំបូងចំពោះនាងខ្ញុំទាំងពីរដែលជានិស្សិត ដោយបានខិតខំ តស៊ូ ព្យាយាមសិក្សាស្រាវជ្រាវ ត្រងត្រាប់ស្តាប់នូវរាល់ការបង្ហាត់បង្រៀនណែនាំរបស់សាស្ត្រាចារ្យទាំងអស់ និងបានជួបប្រទះនូវរាល់ការលំបាកជាច្រើនក្នុងការស្វែងរកឯកសារណាដែលពាក់ព័ន្ធ ព្រមទាំងទទួលបាននូវការពន្យល់ណែនាំ និងកែតម្រូវយ៉ាងយកចិត្តទុកដាក់ ពីសាស្ត្រាចារ្យជំនួយបណ្ឌិត **ព្រុំ រិទ្ធី** ។

ជាការពិតណាស់ឯកសារមួយនេះ នៅមិនទាន់មានភាពល្អឥតខ្ចោះនោះទេ ដែលវាអាចនៅមានចំណុចខ្វះខាតមួយចំនួនដោយមិនបានធ្វើការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែយើងខ្ញុំក៏សង្ឃឹមថា សារណាមួយនេះអាចរួមចំណែកនៅក្នុងការសិក្សារបស់និស្សិតជំនាន់ក្រោយ។

ជាចុងក្រោយ នាងខ្ញុំទាំងពីរនាក់នឹងទន្ទឹងរង់ចាំទទួលយកនូវរាល់មតិរិះគន់ពីគ្រប់មជ្ឈដ្ឋាននានាក្នុងគោលបំណងដើម្បីស្ថាបនា និងកែលម្អរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយដោយក្តីគោរពរាប់អាន។

# មាតិកា

សេចក្តីផ្តើម ................................................ ១

## ជំពូកទី១

## សញ្ញាណទូទៅ

១.១. វត្ថុ ................................................ ៤
១.១.១. អចលនវត្ថុ ................................................ ៤
១.១.២. ចលនវត្ថុ ................................................ ៦
១.២. សញ្ញាណទូទៅនៃការទទួលខុសត្រូវ ................................................ ៧
១.២.១. លក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវ ................................................ ៧
១.២.១.១. កំហុស ................................................ ៧
១.២.១.២. ព្យសនកម្ម ................................................ ៨
១.២.១.៣. ចំណងហេតុផលរវាងកំហុស និង ព្យសនកម្ម ................................................ ១០
១.២.២. ការទទួលខុសត្រូវអំពើអនីត្យនុកូល ................................................ ១០
១.២.២.១. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ................................................ ១១
១.២.២.២. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ................................................ ១២

## ជំពូកទី២

## ការទទួលខុសត្រូវលើអំពើនៃវត្ថុ (លើកលែងសត្វ)

២.១. ការទទួលខុសត្រូវលើអំពើនៃសំណង់អាគារ ................................................ ១៤
២.១.១. ការទទួលខុសត្រូវករណីសំណង់អគាររដ្ឋលរលំ ឬ បាក់ ................................................ ១៥
២.១.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវ ................................................ ១៥
២.១.១.២. ការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ................................................ ១៦
២.១.២. ការទទួលខុសត្រូវករណីសំណង់អគារមានអគ្គិភ័យ ................................................ ១៨
២.១.២.១. សំណង់អគារដែលមានអ្នកគ្រប់គ្រង ................................................ ១៨
២.១.២.២. ភ្លើងកើតឡើងពីអគារ ឬ សំណង់អគារជាប្រភពនៃភ្លើង ................................................ ១៩
២.២. ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណទូទៅ(លើកលែងសំណង់អគារ).... ១៩
២.២.១. ការទទួលខុសត្រូវរបស់អ្នកផលិតវត្ថុ ................................................ ១៩

២.២.២. ការទទួលខុសត្រូវចំពោះវត្ថុមានគ្រោះថ្នាក់ ..... ២១
២.២.៣. ការចូលរួមរបស់វត្ថុក្នុងពេលកើតមានព្យសនកម្ម ..... ២៥

## ជំពូកទី៣

## ការរួចផុតពីការទទួលខុសត្រូវ

៣.១. កិច្ចការពារធម្មានុរូប និងស្ថានភាពចាំបាច់ ..... ២៧
៣.២. ករណីប្រធានសក្តិ ..... ៣០
៣.៣. កំហុសរបស់ជនរងគ្រោះ ..... ៣១
៣.៣.១. កំហុសរបស់ជនរងគ្រោះក្នុងករណីអចលនវត្ថុ ..... ៣១
៣.៣.២. ករណីចលនវត្ថុបំពេញមុខងារអកម្ម ..... ៣២
៣.៤. អំពើរបស់តតិយជន ..... ៣២
៣.៥. ករណីចលនវត្ថុបន្លាស់ទី ..... ៣៣
សេចក្តីសន្និដ្ឋាន ..... ៣៥
អនុសាសន៍ ..... ៣៦
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់បណ្តាលរដ្ឋទាំងអស់នៅក្នុងសកលលោក មិនថារដ្ឋនោះតូច ឬធំក្តី តែងតែបង្កើតឱ្យមាននូវច្បាប់សម្រាប់គ្រប់គ្រងនៅក្នុងរដ្ឋនីមួយៗ។ ការបង្កើតឱ្យមានច្បាប់ទាំងនេះឡើង គឺដើម្បីគ្រប់គ្រងរដ្ឋឬប្រទេសឱ្យមានស្ថេរភាព របៀបរៀបរយ សណ្តាប់ធ្នាប់ល្អ និង សន្តិសុខ នៅក្នុងរដ្ឋ ឬប្រទេសនីមួយៗស្របទៅតាមបរិបទនៃរដ្ឋនោះ ដោយអាស្រ័យទៅតាមប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ សាសនា និងទីតាំងភូមិសាស្ត្រ ក៏ដូចជាប្រវត្តិសាស្ត្រផងដែរ។

នៅក្នុងប្រទេសកម្ពុជា ក៏បានខិតខំបង្កើតនូវច្បាប់ផ្សេងៗជាច្រើន ដើម្បីគ្រប់គ្រងឱ្យមានស្ថេរភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងសន្តិសុខនៅក្នុងប្រទេស។ ការបង្កើតច្បាប់នីមួយៗឡើងនៅក្នុងប្រទេសកម្ពុជាត្រូវបានធ្វើឡើងដោយគោរពទៅតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ត្រូវបានបង្កើតមិនមែនដើម្បីជាផលប្រយោជន៍ដល់បុគ្គលណាម្នាក់នោះទេ តែគឺដើម្បីការពារទៅដល់នូវសិទ្ធិ និងផលប្រយោជន៍សាធារណៈជនទាំងឡាយនៅក្នុងប្រទេស។ ជាក់ស្តែងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានចងក្រងឡើង ដោយគោរពគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ស្របទៅតាមរដ្ឋធម្មនុញ្ញ ក្នុងគោលបំណងការពារផលប្រយោជន៍ និងសិទ្ធិប្រជាពលរដ្ឋ។

ក្នុងក្រមរដ្ឋប្បវេណីត្រូវបានបែងចែកជា៩គន្ថី ដោយនៅក្នុងគន្ថីនីមួយៗក៏មានបែងចែកជាជំពូក ផ្នែក និងកថាខណ្ឌផ្សេងៗ ដែលចាប់ពីបទប្បញ្ញត្តិទូទៅនៅក្នុងគន្ថីទី១ រហូតដល់គន្ថីទី៩ ដែលស្តីពីអវសានប្បញ្ញត្តិ។ ក្នុងនោះដែរក៏សង្កេតឃើញមានការសរសេររៀបរាប់អំពី អំពើអនីត្យានុកូលនៅក្នុងជំពូកទី១៦នៃគន្ថីទី៥នៃក្រមនេះផងដែរ ដោយរៀបរាប់អំពីការទទួលខុសត្រូវលើអំពើអនីត្យានុកូល ដែលបង្កឱ្យមានព្យសនកម្មកើតឡើងដល់អ្នកដទៃ។ កាលណាមានអំពើអនីត្យានុកូលកើតឡើង ដែលបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ ហើយគ្មានការទទួលខុសត្រូវនោះនឹងបង្កឱ្យខាតប្រយោជន៍ដល់ជនរងគ្រោះ ដូចនេះ នៅពេលអំពើអនីត្យានុកូលកើតឡើង ដែលបង្កឱ្យមានព្យសនកម្ម ត្រូវមានការទទួលខុសត្រូវសំណងការខូចខាតដល់ជនរងគ្រោះ ប៉ុន្តែក្នុងនោះដែរក៏អាចមានករណី ដែលអាចរួចផុតពីការទទួលខុសត្រូវផងដែរ។

ទំនាស់ក្រៅកិច្ចសន្យា ត្រូវបានសង្កេតឃើញថាបានកើតឡើងច្រើនក្នុងការរស់នៅប្រចាំថ្ងៃ។ ចំណែកឯការដោះស្រាយទំនាស់គឺមានភាពស្មុគស្មាញ ដោយខ្វះនូវភាពយល់ដឹងខាងផ្នែកច្បាប់រវាងភាគី និងភាគី បង្កឱ្យ

កើតមានជម្លោះ ឈានទៅដល់ការប្តឹងតវ៉ាគ្នាទៅវិញទៅមក។ បុគ្គលទូទៅមួយចំនួននៅមានភាពស្រពិចស្រពិលក្នុងការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី។ ហេតុនេះហើយ នៅពេលមានវិវាទកើតឡើងពួកគេតែងតែចាត់ទុកថាជារឿងព្រហ្មទណ្ឌ ដោយស្ថានទម្ងន់ទោសនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរជាងស្ថានទម្ងន់ទោសនៃការទទួលខុសត្រូវខាងរដ្ឋប្បវេណី ក៏ដូចជាកម្លាចភាគីម្ខាងទៀតឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែ វាក៏មិនមែនមានន័យថាវិវាទរឿងរដ្ឋប្បវេណីពុំមានមូលហេតុពីបទល្មើសព្រហ្មទណ្ឌដែរ មានន័យថា ការធ្វើបណ្តឹងក្នុងការទទួលខុសត្រូវរដ្ឋប្បវេណីអាចក្នុងករណីជាមូលហេតុព្រហ្មទណ្ឌ ឬមូលហេតុរដ្ឋប្បវេណី ឬមូលហេតុទាំងពីរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សានេះ និងបង្ហាញអំពីលក្ខខណ្ឌទាំងឡាយ ដែលនាំឱ្យកើតមានកាតព្វកិច្ចទទួលខុសត្រូវ ឬមិនទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ បូករួមនិងការស្វែងរកនីតិវិធីដោះស្រាយវិវាទឱ្យមានប្រសិទ្ធិភាព និងកាត់បន្ថយបញ្ហាវិវាទក្រៅកិច្ចសន្យាតាមរយៈការបង្កើនការយល់ដឹងដែលមានចំណុចដូចជា៖

១. តើវត្ថុគ្មានវិញ្ញាណអ្វីខ្លះដែលអាចបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ?

២. តើលក្ខខណ្ឌណាខ្លះដែលមានអានុភាពចងកាតព្វកិច្ច ឬពុំអាចចងកាតព្វកិច្ចកម្មសិទ្ធិករនៃវត្ថុគ្មានវិញ្ញាណឱ្យធ្វើការទទួលខុសត្រូវ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសិក្សាស្វែងយល់អំពីមូលហេតុដែលនាំឱ្យមានការទទួលខុសត្រូវលើអំពើអនីត្យានុកូល ក្នុងករណីវត្ថុ ( លើកលែងសត្វ ) របស់កម្មសិទ្ធិករបង្កឱ្យមានព្យសនកម្មដល់ភាគីរងគ្រោះ។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវមួយនេះមានបំណងចង់បង្ហាញអំពីមូលហេតុដែលនាំឱ្យរួចផុតពីការទទួលខុសត្រូវផងដែរ។ ទន្ទឹមនឹងនេះ ជាការចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិដោយចែករំលែកពុទ្ធិដល់មិត្តៗនិស្សិតអ្នកអានក៏ដូចជាសាធារណជនទូទៅ សម្រាប់ជាស្មារតីមួយចំណែកក្នុងការបង្កើនការយល់ដឹងនៃការដោះស្រាយវិវាទក្រៅកិច្ចសន្យា ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំនាក់ទំនងសង្គមក្នុងជីវភាពប្រចាំថ្ងៃ ស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ និងត្រូវចាត់ចូលជាអំពើគតិយុត្តកាលណាវាបង្កើតឱ្យមានអានុភាពខាងផ្លូវច្បាប់ បើទោះបីជាវាស្ថិតនៅក្រៅឆន្ទៈរបស់បុគ្គល ក៏ច្បាប់នៅតែកំណត់ឱ្យជាប់កាតព្វកិច្ច។ តួយ៉ាង អត្ថបទស្រាវជ្រាវក្រោមប្រធានបទ " **ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ** " មួយនេះមានទំហំនៃការស្រាវជ្រាវ ដែលផ្តោតលើគោលការណ៍ទូទៅនៃការទទួលខុសត្រូវរបស់កម្មសិទ្ធិករចំពោះ

វត្ថុ ( លើកលែងសត្វ ) ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន រួមជាមួយនឹងមូលហេតុនាំឱ្យរួចផុតពីកាតព្វកិច្ចនេះផងដែរ។

មួយវិញទៀត ដែនកំណត់នៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើសកម្មភាព ឬអំពើខាងសម្ភារៈមិនចំណុះឱ្យឆន្ទៈបុគ្គល ហើយជារឿយៗត្រូវបានកត់សម្គាល់ថាបានបង្កជាវិវាទក្នុងករណីមួយចំនួនដែលកំណត់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ននេះ ដោយមានក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ជាសំអាង និងមិនផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដោយប្រធានបទស្តីពី " **ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ** " មានបំណងអោយអ្នកអានបានយល់ដឹងនូវគោលការណ៍នៃការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង ដើម្បីជាទុនមួយក្នុងការយល់ដឹងដ៏មានសារៈសំខាន់សម្រាប់ជាប្រយោជន៍ដល់ការស្វែងយល់ន័យ ចំណុចមូលដ្ឋានសំខាន់ៗនៃការទទួលខុសត្រូវលើការខូចខាតដែលកើតចេញពីវត្ថុ ( លើកលែងសត្វ )។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះគឺបានរួមចំណែកលើកស្ទួយភាសាជាតិ ដោយបង្កើនឯកសារស្រាវជ្រាវជាភាសាខ្មែរ រួមទាំងបង្កើនឯកសារអំពីរដ្ឋប្បវេណី ដែលជាកាតព្វកិច្ចនៃអំពើអនីត្យានុកូល និងការទទួលខុសត្រូវបន្ថែមទៀត ដើម្បីផ្តល់ភាពងាយស្រួលកក្នុងការស្វែងយល់ និងមានភាពងាយស្រួលរកផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

តាមរយៈការសិក្សា ការអាន ការស្រាវជ្រាវ និងការស្វែងយល់ ដើម្បីទទួលបានឯកសារផ្សេងៗដែលទាក់ទងទៅនឹងគោលការណ៍ទូទៅនៃការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ សម្រាប់ជាជំនួយស្មារតីដល់មិត្តអ្នកអាន និក្ខេបបទនេះចេញជា ០៣ ជំពូកដើម្បីយល់កាន់តែច្បាស់និងស៊ីជម្រៅទៅលើចំណោទបញ្ហាដែលបានលើកឡើងទាក់ទងទៅនឹងប្រធានបទទាំងមូល មានជាអាទិ៍៖

ជំពូកទី១. សញ្ញាណទូទៅ

ជំពូកទី២. ការទទួលខុសត្រូវលើអំពើនៃវត្ថុ ( លើកលែងសត្វ )

ជំពូកទី៣. ការរួចផុតពីការទទួលខុសត្រូវ

# ជំពូកទី១

# ជំពូកទី១

# សញ្ញាណទូទៅ

ការទទួលខុសត្រូវលើអំពើនៃវត្ថុ គឺជាផ្នែកមួយនៃការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ យោងតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បុគ្គលគ្រប់រូបមានសិទ្ធិ សេរីភាពដូចៗគ្នា បុគ្គលគ្រប់រូបមិនអាចបំពានដល់សិទ្ធិរបស់អ្នកដទៃបានឡើយ ។ កាលណាមានការបំពានសិទ្ធិកើតឡើងបុគ្គល ដែលបំពានសិទ្ធិអ្នកដទៃនោះត្រូវទទួលខុសត្រូវរដ្ឋប្បវេណី ។ ដូចគ្នាដែរកាលណាដែលវត្ថុមួយបានធ្វើឱ្យកើតមានការខូចខាតដល់អ្នកដទៃកើតឡើង មិនថាការខូចខាតលើរូបកាយ ការខូចខាតសម្ភារៈ ឬការខូចខាតផ្លូវចិត្តនោះទេ ត្រូវមានការទទួលខុសត្រូវសងសំណងនៃការខូចខាត ហើយអ្នកដែលមានករណីកិច្ចទទួលខុសត្រូវគឺជាអ្នកមានសិទ្ធិ ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើវត្ថុនោះ ។ ការទទួលខុសត្រូវលើអំពើរបស់វត្ថុ(លើកលែងសត្វ) នេះត្រូវធ្វើឡើង ទៅតាមទំហំ និងលក្ខខណ្ឌនៃការខូចខាតដែលវត្ថុនោះបានបង្កឡើង ។

ហេតុដូចនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យស៊ីជម្រៅទៅលើប្រធានបទ ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ ត្រូវសិក្សាអំពីវត្ថុ និងសញ្ញាណនៃការទទួលខុសត្រូវ។

## ១.១. វត្ថុ

វត្ថុសំដៅទៅលើរបស់ដែលមានរូបរាងជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។[1] ជាឧទាហរណ៍ វត្ថុជាសារធាតុឧស្ម័នមានដូចជាហ្គាស អុកស៊ីសែន ,វត្ថុជាសារធាតុរាវមានដូចជា ទឹក ទឹកក្រូច និងវត្ថុជាសារធាតុរឹងមានដូចជា តុ ដុំតដ្ឋ ឡាន ជាដើម។ យោងតាមនិយមន័យខាងលើ យើងអាចកំណត់បានម្យ៉ាងទៀតថា វត្ថុអាចជារបស់មានវិញ្ញាណ និងរបស់គ្មានវិញ្ញាណ។ គ្មានវិញ្ញាណ មានដូចជាសៀវភៅ សំណង់អគារ និងអាវុធ ជាដើម។ ចំណែកឯវត្ថុមានវិញ្ញាណវិញ គឺសំដៅលើសត្វ។ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាក៏បានកំណត់អំពីប្រភេទនៃវត្ថុផងដែរ ។ ដោយយោងតាមក្រមរដ្ឋប្បវេណី វត្ថុត្រូវបានគេបែងចែកជាពីរប្រភេទដាច់ដោយឡែកពីគ្នា គឺ អចលនវត្ថុ និង ចលនវត្ថុ ។[2]

### ១.១..១. អចលនវត្ថុ

អចលនវត្ថុសំដៅលើដីធ្លី និងវត្ថុជាប់លើដីហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍[3]មានន័យថាអលនវត្ថុសំដៅទៅលើវត្ថុជាប់នៅលើដី ហើយជាវត្ថុដែលតាំងភ្ជាប់យ៉ាងមាំ

[1] មាត្រា ១១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] មាត្រា ១២០ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[3] មាត្រា ១២០ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទៅនឹងដី ដែលគេចាត់ទុកជាផ្នែកមួយនៃដី។ អចលនវត្ថុគឺជាវត្ថុ ដែលមានរូប (ដី និង អាគារ) តែមិនរួមបញ្ចូលវត្ថុទាំងឡាយ ដែលអាចផ្តាច់ ឬ ដកចេញមិនបណ្តាលឱ្យខូចខាតដល់ដីនោះទេ។ ប៉ុន្តែគួរបញ្ជាក់ផងដែរថាអចលនវត្ថុដែលជាដីធ្លីមិនធ្វើការសិក្សានោះទេ គឺនឹងធ្វើការសិក្សាទៅលើអចលនវត្ថុ ដែលជាសំណង់ អគារជាដើម ។ អចលនវត្ថុត្រូវបានបែងចែកជាបីប្រភេទ គឺអចលនវត្ថុពីកំណើត អចលនវត្ថុតាមការកំណត់របស់ច្បាប់ និង អចលនវត្ថុពីភ័ព្វវាសនា[4] ។

- **អចលនវត្ថុពីកំណើត** គឺ ដីធ្លី គេហដ្ឋាន ដែលមានសង់លើគ្រឹះ ឬ សង់ដោយបាយអរ និង ឥដ្ឋសំណង់ទាំងឡាយ បើរុះរើទៅនោះនាំឱ្យបាត់បង់តម្លៃជាសាធាតុ។ អចលនវត្ថុពីកំណើតមានដីធម្មជាតិដូចជា ដីព្រៃឈើ ដីដាំដុះ ដីទុកចោលឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរ និងសំណង់ ឬ ការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬ ផ្លាស់ប្តូរកន្លែងបាន។
- **អចលនវត្ថុតាមការកំណត់របស់ច្បាប់** មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និង ចលនវត្ថុដែលបានកំណត់ដោយច្បាប់ជាអលនវត្ថុ។ ដែលអាចចាត់ទុកថាអចលនវត្ថុតាមការកំណត់របស់ច្បាប់ នោះគឺវត្ថុដែលច្បាប់តម្កល់ឱ្យនៅក្នុងរបៀបជាអចលនវត្ថុពីកំណើត ថ្វីបើអាចរំកិលបាន។ អចលនវត្ថុទាំងឡាយនោះ គឺវត្ថុដែលមានចំណុះ ៣០ តោនឡើងទៅ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ[5] ។ ឧទាហរណ៍៖ កប៉ាល់ និង ផ្ទះដែលមានចំណុះ៣០តោនឡើងជាដើម។
- **អចលនវត្ថុពីភ័ព្វវាសនា** មានឥរិយាបទជាចលនវត្ថុ ប៉ុន្តែត្រូវចាត់ទុកដូចជាអចលនវត្ថុដែរ ពីព្រោះវាត្រូវភ្ជាប់ខ្លួនជាបរិវារនៃអចលនវត្ថុតាំងពីកំណើតដែលគ្រាន់តែជាបន្ទាប់បន្សំប៉ុណ្ណោះ ប៉ុន្តែត្រូវចាត់ទុកជាអចលនវត្ថុ។ អចលនវត្ថុពីភ័ព្វវាសនាអាចចាត់ចែងតាមបញ្ញត្តិស្តីពីសមាសភាគនៃអចលនវត្ថុ និង វត្ថុចំណុះបាន។ អចលនវត្ថុពីភ័ព្វវាសនាមានវត្ថុដែលជាប់នឹងដី ឬ បញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបែកចេញបានដោយមិនធ្វើឱ្យមានការខូចខាត ឬមិនដូរសភាពដើម ដូចជាដើមឈើ ឧបករណ៍តែងលម្អជាដើម[6] ។ ដើម្បីឱ្យចលនវត្ថុតាំងពីកំណើតក្លាយជាអចលនវត្ថុតាមភ័ព្វវាសនា ត្រូវមានលក្ខខណ្ឌ២គឺ៖

[4] មាត្រា ២ ច្បាប់ភូមិបាល ឆ្នាំ២០០១

[5] មាត្រា ៩ ច្បាប់ភូមិបាល ឆ្នាំ១៩៩២

[6] មាត្រា ២ កថាខណ្ឌទី២ ច្បាប់ភូមិបាល ឆ្នាំ២០០១

- ចលនវត្ថុ និង អចលនវត្ថុ ត្រូវជាកម្មសិទ្ធិរបស់កម្មសិទ្ធិករតែមួយ
- កម្មសិទ្ធិករត្រូវបង្ហាញឆន្ទៈភ្ជាប់ចលនវត្ថុនឹងអចលនទ្រព្យពីកំណើតនោះ ។

### ១.១.២. ចលនវត្ថុ

ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ដែលអាចផ្លាស់ទីបាន ឬអាចដកចេញបានដោយមិនធ្វើឱ្យខូចទ្រង់ទ្រាយដើមរបស់វត្ថុអ្វីមួយ[7] ។ ចលនវត្ថុជាវត្ថុដែលអាចរំកិល ឬ ផ្លាស់ប្តូរទីតាំងបាន ដូចជារបស់របរផ្ទាល់ខ្លួន ឬ ចលនទ្រព្យដែលជាកម្មវត្ថុនៃកម្មសិទ្ធិ ហើយមិនត្រូវបានគេចាត់ប្រភេទជាអចលនវត្ថុ។ ឧទាហរណ៍៖ ឡាន ម៉ូតូ កាំភ្លើង...។ ប្រភេទនៃចលនវត្ថុ ត្រូវបានបែងចែកជាបីមានដូចជា ចលនវត្ថុពីកំណើត ចលនវត្ថុគតិយុត្ត និង ចលនវត្ថុតាមកាលទុករណ៍[8]។

- **ចលនវត្ថុពីកំណើត[9]៖** គឺជាទ្រព្យមើលឃើញផ្ទាល់ភ្នែក (រូបិយ) ហើយអាចផ្លាស់ប្តូរទីកន្លែងបានដោយខ្លួនឯង ឬត្រូវទទួលកម្លាំងចលករពីខាងក្រៅជួយ មានដូចជា ម៉ូតូ កង់ ទូ សត្វពាហនៈ។
- **ចលនវត្ថុដោយការសន្មតរបស់ច្បាប់[10] (អរូបិយ) ៖** ការសន្មតនេះមានតែទៅលើវត្ថុអរូបិយដែលជាសិទ្ធិ ឬ ពាក្យបណ្តឹងទៅលើទ្រព្យដែលមិនមែនជាអចលនវត្ថុ។ នៅក្នុងក្រមរដ្ឋប្បវេណីក៏បានកំណត់ផងដែរថា ចំពោះទ្រព្យសម្បត្តិគ្មានរូបរាង ប៉ុន្តែអាចគ្រប់គ្រងបាន ត្រូវចាត់ទុកជាចលនវត្ថុផងដែរ លើកលែងតែមានបញ្ញត្តិច្បាប់ពិសេស[11] ។ ទ្រព្យសម្បត្តិគ្មានរូបរាង គឺជាវត្ថុអរូបិយមាន ដូចជា សិទ្ធ អគ្គីសនី កម្តៅ ពន្លឺ ជាដើម។ ជាក់ស្តែងថាមពលអគ្គិសនី គេអាចគ្រប់គ្រងវាបាន ដូច្នេះគេចាត់ទុកវាជាទ្រព្យសម្បត្តិគ្មានរូបរាង ដែលជាចលនវត្ថុផងដែរ។ ចំពោះចំណុចនៃទ្រព្យសម្បត្តិគ្មានរូបរាងនេះនឹងមិនលើកយកមកធ្វើការសិក្សានៅក្នុងប្រធានបទនេះទេ។
- **ចលនវត្ថុដោយកាលាទិករណ៍[12]៖** ជាវត្ថុកើតពីធម្មជាតិ ឬមនុស្សអ្នកដាំ ហើយឱ្យផលតាមកាលវេលាកំណត់នាពេលខាងមុខ។ ជាឧទាហរណ៍ចលនវត្ថុដោយកាលាទិករណ៍មាន ដូចជាដំណាំស្រូវ ពោត ស្វាយ ចេក បន្លែ ជាដើម។

---

[7] មាត្រា ១២០ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] ហាប់ ផល្លី នីតិរដ្ឋប្បវេណី ឆ្នាំ២០១១ ទំព័រ៤២-៤៣

[9] ហាប់ ផល្លី នីតិរដ្ឋប្បវេណី ឆ្នាំ២០១១ ទំព័រ៤២

[10] ហាប់ ផល្លី នីតិរដ្ឋប្បវេណី ឆ្នាំ២០១១ ទំព័រ៤២

[11] មាត្រា ១២០ កថាខណ្ឌទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] ហាប់ ផល្លី នីតិរដ្ឋប្បវេណី ឆ្នាំ២០១១ ទំព័រ៤៣

ដោយហេតុថា ចលនវត្ថុជាប្រភេទនៃវត្ថុដែលអាចធ្វើការបម្លាស់ទីបានបែបនេះ ទើបវាត្រូវបានចាត់ទុកថាជាវត្ថុសកម្ម ដែលអាចមានចលនា ឬអំពើប៉ះទង្គិចទៅលើបុគ្គលណាមួយបណ្តាលឱ្យមានការខូចខាតកើតឡើង ។

## ១.២. សញ្ញាណទូទៅនៃការទទួលខុសត្រូវ

យោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកម/១២០៧/០៣០ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ បានចែងពីការទទួលខុសត្រូវរដ្ឋប្បវេណីនៅពេលដែលកើតមានព្យសនកម្មកើតឡើងដោយអំពើនៃវត្ថុ (លើកលែងសត្វ) ដែលបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ។ ការខូចខាតដែលបានកើតឡើង ដែលបណ្តាលមកពីអំពើនៃវត្ថុអ្នកគ្រប់គ្រង ឬកម្មសិទ្ធិករនៃវត្ថុត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាត ដល់ជនរងគ្រោះ ដោយសងសំណងនៃការខូចខាតនោះទៅតាមទំហំនៃព្យសនកម្មដែលបានកើតឡើង។ កម្មសិទ្ធិករត្រូវមានកាតព្វកិច្ចទទួលខុសត្រូវសងសំណងនៃការខូចខាត លើព្យសនកម្មដែលបណ្តាលមកពីអំពើនៃវត្ថុទៅតាមលក្ខខណ្ឌនៃការទទួលខុសត្រូវ និងការទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី ដែលមានកំណត់ក្នុងច្បាប់។

### ១.២.១. លក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវ

ការទទួលខុសត្រូវអាចកើតមានឡើង លុះត្រាមានការខូចខាតកើតមានឡើង ដោយស្របទៅតាមលក្ខខណ្ឌដើម្បីដាក់បន្ទុកទៅលើអ្នកបង្ក ឬកម្មសិទ្ធិករនៃវត្ថុឱ្យធ្វើការទទួលខុសត្រូវទៅលើការខូចខាតដែលកើតមានឡើង ដោយសងជាសំណងដើម្បីជួសជុលទៅលើការខូចខាត ឬព្យសនកម្មនោះ។

លក្ខខណ្ឌនៃការទទួលខុសត្រូវសំណងនៃការខូចខាតមានបីគឺ កំហុស, ព្យសនកម្ម និង ចំណងហេតុផលរវាងកំហុស និងព្យសនកម្ម។

#### ១.២.១.១. កំហុស

កំហុសគឺជាអក្បកិរិយារបស់មនុស្សម្នាក់ ដែលកើតឡើងដោយសារការខ្ជីខ្ជា ការធ្វេសប្រហែស មិនយកចិត្តទុកដាក់របស់ខ្លួន ការមិនគោរពកិច្ចសន្យា( កំហុសក្នុងកិច្ចសន្យា) ឬមិនបំពេញករណីកិច្ចរបស់ខ្លួនដែលមិនបង្កឱ្យការខូចខាតដល់អ្នកដទៃ (កំហុសរដ្ឋប្បវេណី)។

យោងតាមមាត្រា៧៥២ នៃក្រមរដ្ឋប្បវេណីកំហុសមានពីរប្រភេទគឺៈ

**-កំហុសដោយចេតនាៈ** គឺជាកំហុសដែលបង្កើតឡើងពីឆន្ទៈរបស់ចារីតែម្តង។ កំហុសដោយចេតនាអាចជាធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ និងរដ្ឋប្បវេណីផងដែរ។ កំហុសចេតនានៅក្នុងប្រព័ន្ធនៃអំពើអនីត្យានុកូលរបស់កម្ពុជា

នេះគឺទាមទារឱ្យមានការទទួលខុសត្រូវចំពោះឆន្ទៈដែលព្យាករណ៍នូវការកើតឡើងនៃលទ្ធផល និងយល់ព្រមឱ្យលទ្ធផលនោះកើតឡើង ។

**-កំហុសដោយអចេតនា៖** គឺជាកំហុសដែលបង្កើតឡើងដោយការធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្នក្នុងការមើលថែទាំ ភាគច្រើនជាកំហុសផ្នែករដ្ឋប្បវេណី។ កំហុសអចេតនានេះ គឺជាការបំពានករណីយកិច្ចព្យាករណ៍ទុកជាមុន និងករណីយកិច្ចជៀសវាង ហើយករណីកិច្ចទាំងពីរនេះដាក់បន្ទុកលើភាគី តែនៅក្នុងករណីដែលការព្យាករណ៍ទុកជាមុន និងការជៀសវាងអាចមានតែប៉ុណ្ណោះ (ច្បាប់មិនដែលចាប់បង្ខំភាពអលទ្ធភាពនោះទេ)[13] ។ ក្នុងករណីដែលបុគ្គលណាម្នាក់ដែលមានឋានៈក្នុងសង្គមដូចអ្នកប្រព្រឹត្តអំពើនោះ អាចព្យាករណ៍បានអំពីការកើតឡើងនៃលទ្ធផល តាមប្រក្រតី ហើយអ្នកប្រព្រឹត្តអំពើនោះមានករណីយកិច្ចជៀសវាងលទ្ធផលនោះ តែមិនបានជៀសវាងឱ្យផុតពីលទ្ធផលនោះទេ អ្នកប្រព្រឹត្តអំពើនោះត្រូវបានចាត់ទុកថាមានកំហុស ។ ចំពោះកំហុសអចេតនានេះ មិនមែនយកឆន្ទៈខាងផ្លូវចិត្ត (ភាពអាចព្យាករណ៍បាន) របស់សាមីខ្លួនអ្នកប្រព្រឹត្តអំពើនោះមកប្រើនោះទេ គឺបានយកទស្សនៈនៃឆន្ទៈប្រក្រតី ។[14]

**១.២.១.២. ព្យសនកម្ម**

ព្យសនកម្ម សំដៅដល់ការធ្វើឱ្យខូចខាត ឬសេចក្ដីវិនាសអន្តរាយដល់រូបកាយក្ដី ដល់សម្ភារៈក្ដី ដល់ផ្លូវចិត្តក្ដី ដែលបណ្ដាលមកពីអំពើរបស់អ្នកដទៃ[15] ។

ព្យសនកម្មមានបីប្រភេទ៖

- ព្យសនកម្មផ្នែកសម្ភារៈ គឺជាការខូចខាតដែលប៉ះពាល់ដល់បេតិកភណ្ឌរបស់បុគ្គល។
- ព្យសនកម្មផ្នែករាងកាយ គឺជាការប៉ះពាល់ដល់រូបរាងកាយរបស់ជនរងគ្រោះ ឬរហូតដល់អាយុជីវិតរបស់ជនរងគ្រោះ។
- ព្យសនកម្មផ្នែកផ្លូវចិត្ត គឺជាការខូចខាតប៉ះពាល់ផ្លូវចិត្តរបស់ជនរងគ្រោះ។

ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត[16] ។

[13] សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ ទំព័រ៩៣

[14] សេចក្ដីកំណត់ក្រមរដ្ឋប្បវេណី ភាគ៣

[15] សន្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១

[16] មាត្រា ១៤ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

យោងតាមក្រមរដ្ឋប្បវេណីការជួលជុលព្យសនកម្មមានបី គឺ សំណងផ្នែករូបរាងកាយ, សំណងផ្នែកសម្ភារៈ និងសំណងផ្នែកផ្លូវចិត្ត ។

- **សំណងផ្នែករូបរាងកាយ៖** ជនរងគ្រោះដែលទទួលរងដោយការបំពានរូបរាងកាយ អាចទាមទារសំណងការខូចខាតចំពោះទ្រព្យសម្បត្តិ រួមទាំងសោហ៊ុយព្យាបាល ប្រាក់ចំណូលនៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ទុកក្រោយពីការព្យាបាល ។ បើអំពើអនីត្យានុកូលបណ្តាលឱ្យបាត់បង់ដល់ជីវិត ជនរងគ្រោះអាចទទួលសិទ្ធិទាមទាររាល់ការចំណាយផ្សេងៗ ដែលបានបាត់បង់ ឬមានករណីកិច្ចត្រូវបង់ និងប្រាក់ចំណូលដែលមិនបានទទួលចាប់ពីក្រោយពេលរងគ្រោះរហូតដល់ទទួលមរណភាព ។ បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយច្បាប់ទំនៀមទម្លាប់ ឬដោយកិច្ចសន្យាអាចទាមទារនូវទ្រព្យសម្បត្តិ ដែលខ្លួនមិនបានទទួលដោយមរណភាពរបស់ជនរងគ្រោះ សោហ៊ុយចេញជំនួសជនរងគ្រោះ និងសោហ៊ុយធ្វើបុណ្យសពជាអាទិ៍ ។[17]
- **សំណងផ្នែកសម្ភារៈ៖** អំពើអនីត្យាកូល ដែលបណ្តាលឱ្យមានការបែកបាក់បាត់បង់ខូចខាតនូវវត្ថុ ឬទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ ជនរងគ្រោះពីអំពើនោះ អាចទាមទារនូវសំណងតម្លៃនៃវត្ថុ ឬទ្រព្យសម្បត្តិដែលបែកបាក់ ឬសោហ៊ុយជួសជុលជាអាទិ៍ ។[18] ឧបមាថា អំពើនៃវត្ថុបានធ្វើឱ្យរថយន្តមួយទទួលរងរងនូវការខូចខាត ហើយរថយន្តនោះមានតម្លៃ ១,០០០ ដុល្លារអាមេរិក ក៏ប៉ុន្តែប្រសិនបើធ្វើការជួសជុលរថយន្តនោះ គឺអស់សោហ៊ុយត្រឹមតែ៥០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ក្នុងករណីនេះតុលាការនឹងទទួលស្គាល់ការទាមទារសំណងត្រឹមតែ ៥០០ ដុល្លារអាមេរិក ដែលជាតម្លៃនៃការជួសជុលតែប៉ុណ្ណោះ ដោយយោងតាមខ្លឹមសារនៃមាត្រា ៧៥៩ នៃក្រមរដ្ឋប្បវេណី ។
- **សំណងផ្នែកផ្លូវចិត្ត៖** ជនរងគ្រោះក៏អាចទាមទារសំណងខូចខាត ដោយអំពើអនីត្យានុកូល ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ សតិអារម្មណ៍ ឬឱ្យចុះខ្សោយខាងបញ្ញាស្មារតី ដែលបានកើតឡើងចំពោះខ្លួន ។ ក្នុងករណីនេះ ប្រាក់សំណងជំងឺចិត្តនឹងត្រូវកំណត់ដោយផ្អែកតាមកម្រិតនៃការរងរបួស និងផលវិបាកដែលបន្សល់ទុក ដោយរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និងពេលអនាគតទៀតផង ។

[17] មាត្រា ៧៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា ៧៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**១.២.១.៣. ចំណងហេតុផលរវាងកំហុស និង ព្យសនកម្ម**

ចំណងហេតុផលរវាងកំហុស និងព្យសនកម្ម ត្រូវតែមានជាដាច់ខាត ។ ចំណងហេតុផលត្រូវតែមានពិតប្រាកដ និងដោយផ្ទាល់ ។

ចំណងទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម គឺជាទំនាក់ទំនងរវាងអំពើដែលជាកំហុសជាមួយនឹងការខូចខាតមានន័យថា ព្យសនកម្មបានកើតឡើងភ្លាមៗ ឬបន្ទាប់ពីអំពើប្រព្រឹត្តបានកើតឡើង ឬក៏អាចនិយាយម្យ៉ាងទៀតបានថា ទំនាក់ទំនងហេតុនិងផលនៃការកើតឡើងនៃការខូចខាតចំពោះជនរងគ្រោះ និងកំហុសរបស់ចារី ។ វាជារឿងចាំបាច់ដែលត្រូវកំណត់ទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម ដើម្បីកំណត់ថាចារីបានបង្កឱ្យមានការខូចខាតដល់ជនរងគ្រោះ។ ក្នុងការបង្ហាញឱ្យឃើញនូវអត្ថិភាពនៃទំនាក់ទំនងមួយយ៉ាងពិតប្រាកដ អំពីទំនាក់ទំនងអំពើដែលបានប្រព្រឹត្តជាមួយនឹងព្យសនកម្ម ជាបន្ទុករបស់ជនរងគ្រោះជាអ្នកបញ្ជាក់បង្ហាញថា ចំណងហេតុផលគឺពិតប្រាកដហើយត្រូវតែជាអំពើរបស់ចារីផ្ទាល់[19] ។ ដូចមានចែងក្នុងកថាខណ្ឌទី៣ មាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំពោះកំហុសចេតនា ឬអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុនិងផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និង ការខូចខាតដែលបានកើតឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេស ឬច្បាប់ផ្សេងទៀត។

ដូចករណីថា បុគ្គលម្នាក់បានបើកឡាននៅតាមដងផ្លូវ ហើយក៏ជ្រុលទៅប៉ះជាមួយនឹងបុគ្គលម្នាក់ទៀតដែលកំពុងជិះម៉ូតូស្របផ្លូវគ្នា បណ្តាលឱ្យម៉ូតូបុគ្គលម្នាក់ទៀត ទទួលរងការខូចខាតបែកស្តុបខាងក្រោយ។ ក្នុងករណីនេះ ចំណងហេតុនិងផលគឺ ស្ថិតនៅត្រង់បុគ្គលជាម្ចាស់ឡាន បានបើកឡានទៅប៉ះម៉ូតូបុគ្គលម្នាក់ទៀត បណ្តាលឱ្យម៉ូតូរបស់បុគ្គលម្នាក់ទៀតនោះ រងការខូចខាត។

**១.២.២. ការទទួលខុសត្រូវអំពើអនីត្យានុកូល**

ការទទួលខុសត្រូវលើអំពើអនីត្យានុកូល អាចកើតឡើងលុះត្រាតែមានការខូចខាតកើតឡើង ។ ការខូចខាតនោះវាអាចកើតចេញពីរឿងក្តីរដ្ឋប្បវេណី ឬខ្លះទៀតវាអាចទាក់ទងនិងមូលហេតុព្រហ្មទណ្ឌ ។ អំពើអនីត្យានុកូលក៏អាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង ព្រមទាំងជាអំពើល្មើសផ្នែករដ្ឋប្បវេណីផងក៏បានដែរ ។ ក្នុងករណីបែបនេះអំពើល្មើសនាំឱ្យមានបណ្តឹងពីរប្រភេទគឺ បណ្តឹងអាជ្ញា (បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាព (ភាពមានកំហុស) នៃជនល្មើស និងផ្តន្ទាទោសជននេះតាម

[19] ញឹក វុធ្ធី នីតិកាតព្វកិច្ច ភាគ២

ច្បាប់កំណត់) និងបណ្តឹងរដ្ឋប្បវេណី (បណ្តឹងរដ្ឋប្បវេណីមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធន់ល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល) ។[20]

**១.២.២.១. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី**

មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីត្រង់កថាខណ្ឌទី១ បានកំណត់ថា បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍របស់ជនដទៃដោយកំហុសចតនា ឬ ដោយអចតនាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ។ កាលណាអំពើអនីត្យានុកូលកើតឡើងដែលបង្កឱ្យមានការខូចខាតដល់អ្នកដទៃ ប៉ុន្តែមិនបានបំពេញនូវធាតុផ្សំនៃបទល្មើសនោះទេ បុគ្គលដែលប្រព្រឹត្តអំពើនោះមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ គឺទទួលខុសត្រូវតែសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

ហេតុនេះការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ជាទណ្ឌកម្មមួយដែលមានគោលបំណងធានានូវការសងសំណងខូចខាតចំពោះជនរងគ្រោះ មានដូចជាសំណងជាប្រាក់ ការហាមមិនឱ្យធ្វើសកម្មភាពណាមួយ ការស្តារឡើងវិញនូវសកម្មភាពដើម ការប្រគល់ត្រលប់វិញ និងការសុំអភ័យទោសជាសាធារណៈ ។ ដោយឡែកជាទូទៅសង្កេតឃើញថាការសងសំណងលើការខូចខាតភាគច្រើនត្រូវបានទូទាត់ជាប្រាក់សម្រាប់ជនរងគ្រោះផ្ទាល់ ព្រោះវាមានភាពងាយស្រួលក្នុងការគណនា ហើយវាក៏ត្រូវបានកំណត់ជាគោលការណ៍ក្នុងច្បាប់[21] ។ ការគណនាចំនួនទឹកប្រាក់ការខូចខាត គឺត្រូវបានវិនិច្ឆ័យទៅលើស្ថានភាពជាក់ស្តែងនៃអំពើ និងទំហំភាពអន្តរាយដែលកើតមានឡើង[22] ។

មួយវិញទៀត សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូលត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល៣ (បី) ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬបើអំឡុងពេល១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។[23]

[20] វុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧ ទំព័រ៥

[21] មាត្រា ៧៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[22] មាត្រា ៧៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] មាត្រា ៧៦៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.២.២.២. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ២ គោលការណ៍នីត្យានុកូលភាព ចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ហើយមានតែទោសដែលដែលមានបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសទោស[24] ។ ការទទួលខុសត្រូវព្រហ្មទណ្ឌគឺ មានលក្ខណៈខុសពីការទទួលខុសត្រូវរដ្ឋប្បវេណីដោយ បុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើ ផ្ទាល់ខ្លួនប៉ុណ្ណោះ[25] ។ ចំពោះបុគ្គលណាម្នាក់ត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌ កាលបើបុគ្គលនោះបានប្រព្រឹត្តអំពើណាមួយដែលមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ។

យោងទៅតាមស្មារតីនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ធាតុផ្សំនៃបទល្មើសមានបី គឺ៖

- **ធាតុផ្សំនីត្យានុកូល (ធាតុច្បាប់)៖** ច្បាប់ដែលបានចាត់ទុកអំពើណាមួយជាបទល្មើស និងមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។
- **ធាតុផ្សំសត្យានុម័ត (ធាតុសម្ភារៈ)៖** គឺជាអង្គហេតុ ឬជាហេតុការទាំងឡាយណាដែលបង្កឱ្យ កើតមាននូវអាកប្បកិរិយាណាមួយ ។ អង្គហេតុទាំងនេះ អាចជាអំពើសកម្ម ឬអំពើអសកម្ម ។ បទល្មើសកើតឡើងក្នុងករណីដែលមានអាកប្បកិរិយាជាសម្ភារៈសម្តែងចេញមកខាងក្រៅតែប៉ុណ្ណោះ ហើយអាកប្បកិរិយាទាំងនេះត្រូវបានហាមឃាត់ដោយច្បាប់ពោលគឺច្បាប់បានបញ្ញត្តិទុកថាជាការបំពាន ដោយសារមានព្យសនកម្មកើតឡើង ។
- **ធាតុផ្សំអត្តនោម័ត៖** កំហុសចេតនា ឬអចេតនារបស់ជនល្មើស ។

កាលណាមានអំពើអនីត្យានុកូលបានកើតឡើងបង្កឱ្យមានព្យសនកម្មដល់អ្នកដទៃ និងបានបំពេញនូវធាតុផ្សំនៃបទល្មើសទាំងបី បុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ហើយក៏ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីដោយសងសំណងនៃការខូចខាតដល់ជនរងគ្រោះផងដែរ ។ ជាទូទៅ ការបង់សំណងជម្ងឺចិត្តជាទណ្ឌកម្មសម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណី និងជាទណ្ឌកម្មដែលផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ ។ ក៏ប៉ុន្តែ ទោសដែលជាទណ្ឌកម្មព្រហ្មទណ្ឌ និងមានគោលដៅចម្បងការពារសង្គមមិនត្រូវបានជាប្រយោជន៍ដល់ជនរងគ្រោះនោះទេ ។ យ៉ាងណាមិញ ប្រាក់ដែលបានពិន័យគឺជាចំណូលទុកជាថវិការបស់រដ្ឋ ចំណែកប្រាក់សំណងជម្ងឺចិត្តវិញ ត្រូវបានទៅជនរងគ្រោះ ។[26]

[24] មាត្រា ២ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[25] មាត្រា ២៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[26] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧ ទំព័រ៥

ជាក់ស្តែងករណីការខូចខាតកើតឡើងដោយសារអំពើនៃយានយន្ត ដែលបានបង្កើតឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់អ្នកដទៃ ដូចជាករណីបើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា, ករណីបើកបរបង្កឱ្យមានរបួស ឬពិការភាពដល់អ្នកដទៃ ជាដើម ត្រូវទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី ។ កាលណាមានទាំងការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណី អ្នកបើកបរ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងការបើកបរយានជំនិះ និងអ្នកគ្រប់គ្រង ឬកម្មសិទ្ធិករ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងករណីយានជំនិះរបស់ខ្លួនបានបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ[27] ។ ក្នុងករណីនេះអាចមានពីរករណី គឺ៖

ទី១. ករណីអ្នកបើកបរជាកម្មសិទ្ធិករ៖ កាលបើអ្នកបើកបរជាកម្មសិទ្ធិករ នោះកម្មសិទ្ធិករនៃយានយន្តនោះត្រូវតែទទួលខុសត្រូវទាំងសំណងផ្នែករដ្ឋប្បវេណីដល់ជនរងគ្រោះ និងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ។

ទី២. ករណីអ្នកបើកបរមិនជាកម្មសិទ្ធិករ៖ ឧទាហរណ៍ ករណីអ្នកបើកបរជាបើកបរជានិយោជិក ដែលបានបើកបររថយន្តឱ្យនិយោជក ហើយនៅពេលកំពុងបំពេញការងារបើកបររថយន្តឱ្យនិយោជកក៏បានបើកជ្រុលទៅបុកអ្នកដំណើរថ្មើរជើងបណ្តាលឱ្យស្លាប់ដោយអចេតនា ។ ករណីនេះនិយោជិកដែលជាអ្នកបើកបររថយន្តនោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ហើយនិយោជកដែលជាកម្មសិទ្ធិករត្រូវតែទទួលខុសត្រូវសងសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ ។

[27] មាត្រា៧២ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងវិសោធនកម្ម ឆ្នាំ២០១៧

# ជំពូកទី២

# ជំពូកទី២

## ការទទួលខុសត្រូវលើអំពើនៃវត្ថុ (លើកលែងសត្វ)

ការទទួលខុសត្រូវលើអំពើនៃវត្ថុ (លើកលែងសត្វ) គឺជាការទទួលខុសត្រូវលើហេតុការណ៍ ដែលបណ្ដាលមកពីអំពើនៃវត្ថុបានបង្កឱ្យមានការខូចខាតកើតឡើង។

ក្រឹត្យច្បាប់លេខ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា បានចែងករណីនេះត្រង់មាត្រា១២៨ ថា៖ កម្មសិទ្ធិករត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃដោយសារទ្រព្យរបស់ខ្លួន ប្រសិនបើការខូចខាតនោះបណ្ដាលមកអំពីការខ្វះការថែទាំ ខ្វះការត្រួតពិនិត្យ ឬក៏ដោយសារសំណង់របស់ខ្លួនសង់មិនបានត្រឹមត្រូវល្អ។

ក្រមរដ្ឋប្បវេណីបារាំងក៏មានឃើញចែងពីការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងវត្ថុ ឬកម្មសិទ្ធិករចំពោះអំពើនៃវត្ថុដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួននៅក្នុងមាត្រា១៣៨៤ វាក្យខណ្ឌទី១ " គេមិនត្រឹមតែទទួលខុសត្រូវពីការខូចខាតដែលគេបង្កឡើងដោយអំពើផ្ទាល់ខ្លួន ប៉ុន្តែទទួលខុសត្រូវផងដែរលើការខូចខាតដែលបានបង្កឡើងដោយអំពើនៃបុគ្គលទាំងឡាយដែលគេត្រូវរ៉ាប់រង ឬដោយវត្ថុដែលស្ថិតនៅក្រោមការមើលថែទាំរបស់គេ " ។[28]

ជាគោលការណ៍ ជនណាដែលមានភារកិច្ចគ្រប់គ្រង ថែទាំរក្សាវត្ថុ ត្រូវតែមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាតដែលបណ្ដាលមកពីអំពើនៃវត្ថុ ដែលខ្លួនគ្រប់គ្រង ថែទាំរក្សានោះ។

ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ ត្រូវបានបែងចែកជាពីរគឺ ការទទួលខុសត្រូវលើអំពើនៃសំណង់អគារ និង ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណទូទៅ (លើកលែងអគារ) ។

### ២.១. ការទទួលខុសត្រូវលើអំពើនៃសំណង់អគារ

សំណង់ សំដៅទៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការរួទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្ដោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខាសំណង់ ឬផលិតផលសំណង់ ។[29] រីឯសំណង់ជាប់នឹងដីត្រូវបានបកស្រាយ ក្នុងន័យទូលាយរួមមាន ផ្ទះ អាគារ ស្ពាន ផ្លូវដែក បង្គោលភ្លើង បង្គោលអង់តែន ពោលគឺគ្រប់សំណង់ដែលភ្ជាប់នឹងដីទាំងអស់ ។[30]

[28] មាត្រា ១៣៨៤ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤

[29] សន្ទានុក្រមច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[30] ឯកឧត្ដម ហ៊ី សោភា អំពើអនីត្យានុកូល

លើសពីនេះទៅទៀត សំណង់ក៏ត្រូវចាត់ទុកជាផ្នែកមួយនៃផលិតផលគ្រឹះក្នុងខឿនសេដ្ឋកិច្ចជាតិដោយសំណង់មាន តួនាទីសំខាន់ ក្នុងការកសាងមូលដ្ឋានសម្ភារៈ បច្ចេកទេសសង្គម សំខាន់ចំពោះកម្ពុជាដែលកំពុងសាងខឿនសេដ្ឋកិច្ចជាតិតាមទិសដៅសេរី ។ ដោយហេតុនេះ រដ្ឋាភិបាលហៅសំណង់ ជាមុខរបរឧស្សាហកម្មធន់ធ្ងន់មួយក្នុងចំណោមឧស្សាហកម្មធន់ធ្ងន់ដ៏ទៃទៀត ។[31] ជាក់ស្តែង នៅក្នុងប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ បានឱ្យនិយមន័យ អគារនិងសំណង់ផ្សេងៗ គឺសំដៅដល់អគារ និងសំណង់ផ្សេងៗដែលសង់ជាប់នឹងដីទោះបីមាន ឬគ្មានជញ្ជាំង ឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារអាផាតមែន ខុនដូ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អាគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គីសនី ព្រលានយន្តហោះ កំពង់ផែ ចំណតយានយន្ត។

កម្មសិទ្ធិករនៃអគារគឺ អាចត្រូវទទួលខុសត្រូវលើការខូចខាតដោយអំពើនៃការរលំបែកបាក់អគារ ឬដោយអំពើអគ្គិភ័យបានកើតឡើងក្នុងអគារ។

## ២.១.១. ការទទួលខុសត្រូវករណីសំណង់អគារដួលរលំ ឬ បាក់

សំណងអគារដែលត្រូវបានសាងសង់ ឬកំពុងសាងសង់ បើមានការដួលរលំ ឬបាក់ស្រុតសំណងអគារនោះកើតមានឡើង ដែលបណ្តាលឱ្យមានព្យសនកម្មដល់ជនរងគ្រោះ មិនថាព្យសនកម្មរូបរាងកាយ ព្យសនកម្មលើសម្ភារៈ ឬព្យសនកម្មផ្លូវចិត្ត ត្រូវតែមានការទទួលខុសត្រូវជួសជុលព្យសនកម្មដល់បុគ្គលទាំងឡាយ ដែលបានទទួលរងគ្រោះពីការដួលរលំ ឬបាក់ស្រុតសំណង់អគារនោះទៅតាមព្យសនកម្មដែលកើតមាន។ កាលណាកើតមានព្យសនកម្មដលើអ្នកដទៃ ត្រូវតែមានការទទួលខុសត្រូវលើសំណងនៃការខូខាតលើជនរងគ្រោះជាដាច់ខាត ។ ការទទួលខុសត្រូវត្រូវមានលក្ខខណ្ឌនៃការទទួលខុសត្រូវ និងអ្នកដែលមានកាតព្វកិច្ចទទួលខុសត្រូវ ។

### ២.១.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវ

កាលណាមានការដួលរលំ ឬ បាក់ស្រុតនូវសំណង់អគារ ឬផ្ទះ មិនថាបានធ្វើការសាងសង់ហើយក្តី ឬកំពុងធ្វើការសាងសង់ក្តី បើមានការខូចខាតដល់អ្នកដទៃកើតមានឡើង ត្រូវមានការការទទួលខុសត្រូវលើសំណងនៃការខូចខាតនោះចំពោះជនរងគ្រោះនោះ ។ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតចំពោះជនរងគ្រោះនេះ ដោយសំណង់អគារដែលដួលរលំ ឬបាក់ត្រូវបានស្ថិតនៅក្នុងលក្ខខណ្ឌពីរសំខាន់ៗ គឺសំណង់មានវិការៈ ឬខ្វះការថែទាំ និង ការធ្វេសប្រហែសនៃការសាងសង់។

[31] សួស ចំរើន គ្រប់គ្រងសំណង់ ឆ្នាំ២០០៣ ទំព័រ១

**ក. សំណង់មានវិការៈ ឬ ខ្វះការថែទាំ**

ការទទួលខុសត្រូវរបស់កម្មសិទ្ធិករនៃអគារ ចំពោះទៅនឹងភស្តុតាងបង្ហាញដោយជនរងគ្រោះថា ការរលំមានមូលហេតុមកពីវិការៈនៃការសាងសង់ ឬខ្វះការថែទាំ ។[32] វិការៈនៃការសាងសង់ មានន័យថាការកើតមានឡើងនូវភាពមិនប្រក្រតីនៅត្រង់ចំណុចណាមួយនៃការសាងសង់ដែលនាំឱ្យសំណង់ ឬអគារមានការដួលរលំ ឬបាក់ស្រុតដែលកើតឡើងដោយសារតែការសាងសង់របស់ស្ថាបត្យករ ឬសហគ្រិនសាងសង់នៃអគារនោះមិនស្របទៅតាមបច្ចេកទេសនៃការសាងសង់ ឬបច្ចេកទេស ឬបញ្ហាគុណភាពដែលបង្កឱ្យមានការខូចខាតនេះកើតមានឡើង។

ករណីសំណង់មានវិការៈអាចបណ្ដាលមកពីអ្នកសាងសង់ ឬករណីខ្វះការថែទាំបណ្ដាលមកពីអ្នកគ្រប់គ្រងសំណង់ឬអគារនោះ ហើយអ្នកគ្រប់គ្រងអាចជាកម្មសិទ្ធិករ ឬមិនមែនកម្មសិទ្ធិករ ហើយបណ្ដាលឱ្យមានព្យសនកម្មកើតឡើងដល់អ្នកដទៃ អ្នកគ្រប់គ្រងអគារ ឬកម្មសិទ្ធិករត្រូវទទួលខុសត្រូវសំណងការខូចខាតលើព្យសនកម្មដែលបានកើតឡើងនោះ។ ប្រសិនបើការដួលរលំ ឬបាក់ស្រុតមួយផ្នែក ឬទាំងស្រុង នោះមិនបណ្ដាលឱ្យមានការខូចខាតដល់អ្នកដទៃទេ គឺគ្មានការទទួលខុសត្រូវឡើយ។

**ខ. ការធ្វេសប្រហែសនៃការសាងសង់**

ការធ្វេសប្រហែសនៃការសាងសង់ មានភាពស្រដៀងគ្នាទៅនឹងវិការៈនៃការសាងសង់ដែរ ដោយហេតុថាវាបង្ហាញពីកំហុសរបស់អ្នកសាងសង់ ដែលមានភាពថ្លោះធ្លោយក្នុងការបំពេញការងារ តួនាទីរបស់ខ្លួនមិនយកចិត្តទុកដាក់ ហើយបណ្ដាលឱ្យមានវិការៈ ។ ហេតុនេះ បើសិនជាមានការខូចខាតប៉ះពាល់ដល់អ្នកដទៃដែលបណ្ដាលមកពីវិការៈនៃសំណង់ កម្មសិទ្ធិករ អាចធ្វើការប្ដឹងទាមទារសំណងនៃព្យសនកម្មវិញបានបន្ទាប់ពីខ្លួនបានជួសជុលការខូចខាតដល់ជនរងគ្រោះរួចហើយ ។

**២.១.១.២ ការទទួលខុសត្រូវរបស់កម្មសិទ្ធិករ**

ការកើតមានព្យសនកម្មដល់អ្នកដទៃ ដោយការបាក់ស្រុត ឬដួលរលំអគារ ត្រូវតែមានការទទួលខុសត្រូវជួសជុលព្យសនកម្ម ដែលបានកើតឡើងដល់ជនរងគ្រោះ ពីកម្មសិទ្ធិករនៃអគារនោះ ។ កម្មសិទ្ធិករនៃអគារត្រូវទទួលខុសត្រូវលើការខូចខាត ដែលបណ្ដាលមកពីការដួលរលំបែកបាក់នៃអគារ ឬសំណង់មានវិការៈ ឬខ្វះការថែទាំ។ កាលណាអគារមានការដួលរលំ ឬបាក់ស្រុត កម្មសិទ្ធិករត្រូវមានកាតព្វកិច្ចទទួលខុសត្រូវសងការខូចខាត ឬជួសជុលព្យសនកម្មដល់ជនរងគ្រោះ ដោយមិនអាចជៀសបាន មិនថាកម្មសិទ្ធិករជាអ្នកគ្រប់គ្រងសំណងនោះ ឬកម្មសិទ្ធិករមិនជាអ្នកគ្រប់គ្រងក៏ដោយ ។

---

[32] ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៣៩

ការទទួលខុសត្រូវរបស់កម្មសិទ្ធិករត្រូវបានបែងចែកជាពីរដូចជា៖

- ករណីអ្នកគ្រប់គ្រងជាកម្មសិទ្ធិករ
- និង ករណីអ្នកគ្រប់គ្រងមិនមែនជាកម្មសិទ្ធិករ។

**ក. ករណីអ្នកគ្រប់គ្រងជាកម្មសិទ្ធិករ**

គ្រប់ករណី គឺកម្មសិទ្ធិករត្រូវតែជាអ្នកទទួលខុសត្រូវតែម្នាក់ឯងចំពោះជនរងគ្រោះ គឺជួសជុលសំណងចំពោះគ្រប់ការខូចខាតដែលជនរងគ្រោះទទួលរង ។

ប្រសិនបើការរលំ បែកបាក់ បណ្តាលមកពីវិការៈនៃការសាងសង់( ដាក់កំហុសដល់ស្ថាបត្យករ ឬសហគ្រិនដែលសាងសង់អាគារ ) កម្មសិទ្ធិករក៏មិនរួចផុតពីការទទួលខុសត្រូវចំពោះការខូចខាតដែលបានបង្កឡើងដែរ។ វាជាសច្ចាធារណ៍មិនអាចប្រឆាំងបានពីកំហុសរបស់កម្មសិទ្ធិករ។ កម្មសិទ្ធិករក្រោយពីរួចផុតពីការខូចខាតដែលទទួលរងដោយជនរងគ្រោះមក ( បង់ប្រាក់ជំងឺចិត្ត ) អាចប្តឹងត្រឡប់ទល់នឹងអ្នកដែលមានកំហុសខាងវិការៈនៃការសាងសង់( ស្ថាបត្យករ សហគ្រិន។ល។ ) ។[33]

ជាក់ស្តែង ករណីបាក់អគារកម្ពស់៦ជាន់ នៅខេត្តកែប កាលពីថ្ងៃទីនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ កន្លងទៅបានបណ្តាលឱ្យមានអ្នករងរបួសមានចំនួន ៥៩នាក់ និងបាត់បង់ជីវិតចំនួន ៣៦នាក់ ។ នៅក្នុងករណីនេះដែរ ត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា «មេការ ជាអ្នកមានកំហុស» ប៉ុន្តែ មេការនោះ រួមទាំងកូនរបស់គាត់ «ក៏បានស្លាប់ជាមួយអ្នកផ្សេងទៀតដែរ» ដោយសារការបាក់រលំអគារនេះ។ ក្នុងករណីនេះដែរ នៅមិនទាន់ឮប្រមុខរដ្ឋាភិបាល ប្រកាសថា មានអ្នកផ្សេង មានកំហុស ឬក៏ត្រូវទទួលខុសត្រូវ ក្នុងរឿងនេះទេ ក្រៅតែពីមេការនោះ។ ក្នុងសន្និសីទកាសែត នៅម៉ោង១២ថ្ងៃត្រង់ នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ ស្តីពីការបិទបញ្ចប់ការរុករកជនរងគ្រោះក្នុងគំនរអគារ សម្តេចនាយករដ្ឋមន្ត្រី ដែលប្រចាំការនៅទីនោះពីដើមរហូតដល់ចប់ បានអះអាងថា ការសាងសង់អគារនេះ មានកំហុស២យ៉ាង គឺទី១ កំហុសផ្នែកគូរប្លង់ និងទី២ កំហុសផ្នែកចាក់ប្លង់សេ។ យ៉ាងណា សម្តេចនាយករដ្ឋមន្ត្រី បានលើកឡើងថា ម្ចាស់អគារ ត្រូវបានចាប់ខ្លួន ហើយត្រៀមនឹងបញ្ជូនទៅតុលាការ។ សម្តេច និយាយថា ចំពោះការប្តឹងទារសំណងរដ្ឋប្បវេណី គឺត្រូវធ្វើទៅតាមច្បាប់ ។[34]

[33] ញឹក វុធ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៣៩

[34] Thmeythmey "បាក់អគារនៅកែប៖ នាយករដ្ឋមន្ត្រីប្រកាសថា អ្នកមានកំហុស បានស្លាប់" ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ គេហទំព័រ ៖ https://thmeythmey.com/m/?page=detail&id=86822 ថ្ងៃចូលគេហទំព័រ ០១ ឧសភា ឆ្នាំ២០២៣

**ខ. ករណីអ្នកគ្រប់គ្រងមិនមែនជាកម្មសិទ្ធិករ**

ក្នុងករណីអ្នកគ្រប់គ្រងមិនមែនកម្មសិទ្ធិករ ប្រសិនបើមានកង្វះខាតក្នុងការថែទាំ ហើយបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់និងកម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ។

បើសិនជាអ្នកគ្រប់គ្រងបានបញ្ជាក់ភស្តុតាងថាខ្លួនបានគ្រប់គ្រងត្រឹមត្រូវនឹងអាចរួចផុតពីការទទួលខុសត្រូវបាន ។ ប៉ុន្តែចំពោះម្ចាស់កម្មសិទ្ធិវិញ ពុំមានបញ្ញត្តិឱ្យលើកលែងដូចនេះទេ ។[35]

ឧទាហរណ៍៖ ក្នុងករណីរបងផ្ទះជួលបានរលំ ហើយបានធ្វើឱ្យអ្នកដើររងរបួស ម្ចាស់ផ្ទះ( ភតិបតី ) និងអ្នកជួល ( ភតិកៈ ) ត្រូវទទួលបន្ទុកនូវសំណងនៃការខូចខាតដោយសាមគ្គីភាព ។

**២.១.២. ការទទួលខុសត្រូវករណីសំណង់អគារមានអគ្គិភ័យ**

អ្នកដែលកាន់កាប់អចលនវត្ថុមួយផ្នែក ឬទាំងអស់ដែលមានអគ្គិភ័យបានចាប់ផ្តើមកើតមាននោះ ត្រូវទទួលខុសត្រូវចំពោះតតិយជន ( ជនដែលគ្មានទាក់ទងក្នុងរឿងជាមួយ ) អំពីការខូចខាតដែលបណ្តាលមកពីអគ្គិភ័យនោះ ប្រសិនបើមានភស្តុតាងថាខ្លួនមានកំហុស ឬកំហុសនៃបុគ្គលដែលជាអ្នកកាន់កាប់ត្រូវទទួលខុសត្រូវ ។[36]

លក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះសំណង់អគារ ដែលមានអគ្គីភ័យមាន៖

- សំណង់អគារដែលមានអ្នកគ្រប់គ្រង
- និងភ្លើងកើតឡើងពីអគារ ឬ សំណង់អគារជាប្រភពនៃភ្លើង។

**២.១.២.១. សំណង់អគារដែលមានអ្នកគ្រប់គ្រង**

ក្នុងករណីអគារមានអគ្គីភ័យ បើសិនជាអគារនោះមានកម្មសិទ្ធិករដែលជាអ្នកកាន់កាប់ ឬមានអ្នកគ្រប់គ្រង ទើបមានការទទួលខុសត្រូវ ចំពោះការខូចខាតលើជនរងគ្រោះ ដោយអាចជាមូលហេតុមកពីការធ្វេសប្រហែសក្នុងការគ្រប់គ្រងវត្ថុ ឬរបស់ដែលអាចបង្កឱ្យមានភ្លើងឆាបឆេះ។ ផ្ទុយទៅវិញ បើអគារ ឬសំណង់នោះពុំមានអ្នកកាន់កាប់ទេ នោះពុំមានជនណាមួយធ្វើការរ៉ាប់រងព្យសនកម្មឡើយ។

ឧទាហរណ៍ លោកស្រី ក បានដាក់ដំបាយទុកចោល ស្រាបតែផ្ទុះកំប៉ុងហ្គាស ធ្វើឱ្យឆាបឆេះផ្ទះរបស់ខ្លួន និងបានរាលដាលដល់ផ្ទះរបស់លោក ខ ធ្វើឱ្យឆាបឆេះផងដែរ ។

ក្នុងករណីនេះ ផ្ទះលោកស្រី ក ជាប្រភពនៃភ្លើង ដែលបណ្តាលឱ្យឆេះរាលដាលដល់ផ្ទះលោក ខ ជាជនរងគ្រោះ ។ ហើយការកើតឡើងករណីអគ្គីភ័យនេះជាកំហុសរបស់កម្មសិទ្ធិករនៃផ្ទះ ដែលជាប្រភពនៃភ្លើង

[35] មាត្រា៧៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] មាត្រា ១៣៨៤ វាក្យខ័ណ្ឌទី២ ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤

ដោយទង្វើខ្ជីខ្ជា និងការខ្វះការប្រុងប្រយ័ត្ន ។ ដូច្នេះក្នុងករណីនេះ លោកស្រី ក ដែលជាកម្មសិទ្ធិករនៃផ្ទះ ដែលជាប្រភពនៃភ្លើង អាចត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតដល់ជនរងគ្រោះ គឺ លោក ខ ។

**២.១.២.២. ភ្លើងកើតឡើងពីអគារ ឬ សំណង់អគារជាប្រភពនៃភ្លើង**

ក្នុងលក្ខខណ្ឌមួយទៀតនៃការទទួលខុសត្រូវករណីមានអគ្គិភ័យ លុះត្រាតែអគារ ឬសំណង់នោះជាប្រភពនៃភ្លើងឆេះ ។ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងអគារដែលជាប្រភពនៃភ្លើងត្រូវទទួលខុសត្រូវលើសំណងខូចខាតដែលបណ្តាលឱ្យមានព្យសនកម្មកើតឡើងដល់អ្នកដទៃ ដោយសារកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងសំណង់អគារនោះ ។ ជនរងគ្រោះជាអ្នកដែលត្រូវទទួលបន្ទុកស្វែងរកភស្តុតាងនៃកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងសំណង់អគារ ដែលជាប្រភពនៃអគ្គិភ័យនោះ ។

## ២.២. ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណទូទៅ(លើកលែងសំណង់អគារ)

ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណទូទៅ គឺជាការទទួលខុសត្រូវលើការខូចខាត បណ្តាលមកពីអំពើរបស់វត្ថុដែលស្ថិតនៅក្រោមការមើលថែទាំរបស់អ្នកថែរក្សា។ តាមគោលការណ៍នេះ យុត្តិសាស្ត្រ និងនីតិវិទូបានបង្កើតទ្រឹស្តីទូទៅនៃការទទួលខុសត្រូវដោយអំពើរបស់វត្ថុគ្មានវិញ្ញាណ(លើកលែងអគារ)។

ការទទួលខុសត្រូវដោយអំពើនៃវត្ថុគ្មានវិញ្ញាណតម្រូវឱ្យមានធាតុផ្សំបីគឺ វត្តមាននៃវត្ថុគ្មានវិញ្ញាណ ឆ្មាំវត្ថុ ឬបុគ្គលដែលមានសិទ្ធិថែរក្សាវត្ថុនោះ និង ការចូលរួមរបស់វត្ថុក្នុងការកើតមានព្យសនកម្ម។

**២.២.១. ការទទួលខុសត្រូវរបស់អ្នកផលិតវត្ថុ**[37]

ករណីនេះជា ស្ថានភាពដែលផលិតករបានផលិត ឬចែកចាយផលិតផលរបស់ខ្លួនទៅឱ្យអ្នកប្រើប្រាស់ ហើយបង្កឡើងជាការប៉ះពាល់ណាមួយទៅដល់អ្នកប្រើប្រាស់ ដូចនេះផលិតករត្រូវមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាតទាំងនោះដែលទទួលរង មកពីការប្រើប្រាស់លផលិតផលដែលខ្លួនបានផលិត ឬចែកចាយទៅឱ្យអ្នកដទៃ ។ ស្របតាមការកំណត់របស់ច្បាប់ ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃដោយមានវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត។ ក្នុងក្រមរដ្ឋប្បវេណីក៏បានសន្មត់បុគ្គលមួយចំនួនជាផលិតករ[38] ដែលជាអ្នកផលិតចលនវត្ថុដូចជាគ្រឿងផ្សំ ឬវត្ថុធាតុដើមណាមួយ ហើយចំពោះអ្នកនាំចូលផលិតផល និងអ្នកបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬអ្នកលក់នៅលើចលនវត្ថុនោះជាដើម។ ដើម្បីឱ្យការទទួលខុសត្រូវនេះអាចកើតឡើងបានលុះត្រាតែសកម្មភាពនៃអំពើនេះវាស្របទៅតាមគោលការណ៍

[37] មាត្រា ៧៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[38] មាត្រា ៧៥១ កថាខណ្ឌទី៣ និង៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បញ្ញត្តិដែលជាលក្ខខណ្ឌអនុវត្តជាមុនសិន។ ស្របតាមបញ្ញត្តិដដែលបានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលនាំឱ្យមានការទទួលខុសត្រូវ[39] ត្រឹមត្រូវតាមច្បាប់៖

- **ចលនវត្ថុដែលផលិតមានវិការៈ៖** ចំណុចនេះសំដៅដល់ការផលិតរបស់ផលិតករ ផលិតដោយខ្វះបច្ចេកទេស ខ្វះអនាម័យដោយប្រើសារធាតុគីមីលើសពីការកម្រិតអនុញ្ញាតសុទ្ធតែជាវិការក្នុងការផលិត។ បញ្ជាក់បន្ថែមចំណុចនេះជាការទទួលខុសត្រូវកើតមានឡើងតែ សម្រាប់ចលនវត្ថុដែលត្រូវបានផលិតប៉ុណ្ណោះ ផ្ទុយទៅវិញអចលវត្ថុដែលកើតឡើងដោយធម្មជាតិគ្មានទេការទទួលខុសត្រូវ។
- **ការខូចខាតបណ្តាលមកពីចលនវត្ថុដែលផលិត៖** សំដៅដល់គ្រោះថ្នាក់ដែលនាំឱ្យមានការខូចខាតដល់អ្នកប្រើប្រាស់ពីចលនវត្ថុដែលត្រូវបានផលិត ដែលគ្រោះថ្នាក់នេះកើតឡើងដោយសារ ការផលិតដោយមានវិការៈ ការប្រើប្រាស់ដោយមានវិការៈ ការរក្សាទុកដោយមានវិការៈ។
- **គ្រោះថ្នាក់មិនសមហេតុផល៖** ជាធម្មតាគ្រប់វត្ថុតែផ្ទុកនូវទាំងគុណវិបត្តិ និងគុណសម្បត្តិ ម្លោះហើយជាទូទៅតែងតែរងនូវផលប៉ះពាល់ខ្លះៗ។ សម្រាប់វត្ថុខ្លះទៀតគេបានដឹងហើយថា អាចនឹងរងនូវផលប៉ះពាល់ខ្លាំង ក៏ប៉ុន្តែដោយសារផលប្រយោជន៍សេដ្ឋកិច្ចមានទំហំធំ ដែលនាំឱ្យគេនៅតែអនុញ្ញាតឱ្យធ្វើអាជីវកម្មបានដោយគ្រាន់តែគេតម្រូវឱ្យធ្វើការផ្សព្វផ្សាយពីផលប៉ះពាល់របស់វាជាសាធារណៈ ដូចជាស្រាមានផលប៉ះពាល់ទៅកាន់ថ្លើមចំពោះអ្នកទទួលទាន រីឯបារីមានផលប៉ះពាល់ទៅដល់សួតជាដើម។ ដូចនេះ គេអាចចាត់ទុកថាគ្រោះថ្នាក់ ឬផលប៉ះពាល់របស់វាជាផលប៉ះពាល់សមហេតុផល។ ផ្ទុយទៅវិញសម្រាប់វត្ថុដែលបង្កើតឡើងនូវផលប៉ះពាល់ដែលខុសពីការរំពឹងទុក ដោយសារតែការប្រើប្រាស់នូវសារធាតុគីមីលើសកម្រិតជាដើមដែលខុសពីលក្ខណៈបច្ចេកទេស ពុំត្រូវបានចាត់ជាគ្រោះថ្នាក់សមហេតុនោះទេ។

ដូចនេះហើយបើសិនជាមានការខូចខាតកើតមានឡើងស្របទៅតាមលក្ខខណ្ឌគោលនៃបញ្ញត្តិនេះ ការទទួលខុសត្រូវរបស់ផលិតករ ឬអ្នកសន្មតថាជាផលិតករត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនេះ។ ការទទួលខុសត្រូវរបស់ផលិតករ ជាការទទួលខុសត្រូវដោយផ្អែកលើស្ថានភាពគ្រោះថ្នាក់នៃវត្ថុដែលខ្លួនផលិតមិនមែនជាការទទួលខុសត្រូវដោយផ្អែកលើកំហុសឡើយ បែបនេះជនរងគ្រោះ ឬអ្នករងគ្រោះមិនចាំបាច់បង្ហាញអំពីកំហុសរបស់ផលិតករទេពេលទាមទារសំណងនៃការខូចខាត។ ដោយឡែកនៅក្នុងស្ថានភាពខ្លះទោះបីលក្ខខណ្ឌត្រូវបានបំពេញហើយក្តីក៏ដោយ ក៏ការទទួលខុសត្រូវនៅតែពុំអាចកើតមានឡើងនោះដែរ។ ជាក់ស្តែងក្នុងក្រមរដ្ឋប្បវេណីបានកំណត់អំពីអញ្ញត្តកម្មចំពោះការទទួលខុសត្រូវរបស់អ្នកផលិតវត្ថុនេះផងដែរ។

[39] មាត្រា ៧៥១ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការទទួលខុសត្រូវចំពោះការខូចខាតនឹងពុំកើតមានឡើងឡើយប្រសិនបើការខូចខាតនោះកើតឡើងនៅក្នុងករណីវិទ្យាសាស្ត្រមិនអាចប្រមាណដឹងអំពីគ្រោះថ្នាក់នៃចលនវត្ថុដែលផលិត[40] ។

ជាធម្មតាផលិតករអាចប្រមាណអំពីភាពគ្រោះថ្នាក់នៃវត្ថុដែលខ្លួនផលិតដោយពឹងផ្អែកទៅលើភាពជឿនលឿននៃវិទ្យាសាស្ត្រដើម្បីធ្វើការសាកល្បង និងវិនិច្ឆ័យបើវិទ្យាសាស្ត្រពុំប្រមាណបានផង ប្រាកដណាស់ផលិតករក៏មិនអាចដឹងអំពីវិការៈ ដែលនឹងបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ឡើយ។ ហេតុនេះហើយផលិតករត្រូវរួចផុតពីការទទួលខុសត្រូវរាល់ការខូចខាត ។

### ២.២.២. ការទទួលខុសត្រូវចំពោះវត្ថុមានគ្រោះថ្នាក់[41]

ដោយសារតែការខូចខាត ដែលកើតចេញពីវត្ថុដែលមានគ្រោះថ្នាក់មានកម្រិតខ្ពស់ ហើយដើម្បីការពារផលប្រយោជន៍ និងដោះស្រាយនូវសំណងដល់ជនរងគ្រោះ ឬអ្នករងគ្រោះឱ្យមានប្រសិទ្ធិភាពខ្ពស់ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងនូវវត្ថុដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ត្រូវទទួលខុសត្រូវសងការខូចខាតដោយមិនចាំបាច់គិតអំពីកំហុសឡើយ។ មិនខុសពីគោលការណ៍ផ្សេងទៀតនៃអំពើអនីត្យានុកូលពិសេសនេះច្បាប់បានកំណត់អំពីលក្ខខណ្ឌដើម្បីឱ្យការទទួលខុសត្រូវអាចកើតមានឡើងបាន។ លក្ខខណ្ឌចម្បងនៃគោលការណ៍គឺ វត្ថុគ្រោះថ្នាក់បានបង្កការខូចខាតដល់អ្នកដទៃ។

ជាការពិតណាស់ប្រសិនបើចង់មានការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់ចាំបាច់អំពើនៃការខូចខាតនោះត្រូវតែបង្កឡើងដោយមាននូវវត្ថុដែលចាត់ទុកថាមានគ្រោះថ្នាក់។ ក្នុងនោះដែរវត្ថុដែលច្បាប់បានសន្មតថាជាវត្ថុគ្រោះថ្នាក់ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណី ដែលមានដូចជា រថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូន គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ដូច្នេះហើយការខូចខាតណាមួយបានកើតឡើងដោយមានវត្ថុមានវត្ថុ ទាំងនេះដែលគេចាត់ទុកវាថាជាវត្ថុគ្រោះថ្នាក់នៅក្នុងហេតុការណ៍។ ស្របគ្នានោះការទទួលខុសត្រូវសំណងការខូចខាតក៏បានកើតឡើងផងដែរទៅកាន់ជនរងគ្រោះ។ លក្ខខណ្ឌមួយផ្សេងទៀត គឺ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងវត្ថុគ្រោះថ្នាក់ លក្ខខណ្ឌនេះគឺសំដៅលើការស្វែងរកអ្នកដែលត្រូវទទួលខុសត្រូវឱ្យបានជាក់លាក់ក្នុងហេតុការណ៍គ្រោះថ្នាក់ដែលបង្កជាការខូចខាត់ត្រូវទាមទារស្វែងរកសមាសភាពបុគ្គលដែលមានឋានៈជា កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងវត្ថុគ្រោះថ្នាក់ដើម្បីធ្វើការទទួលខុសត្រូវលើព្យសនកម្មមួយពុំនោះការទទួលខុសត្រូវក៏មិនអាចកើតឡើងបានដែរ ប្រសិនបើគ្មានអ្នកមានកាតព្វកិច្ចត្រូវទទួលខុសត្រូវនោះ

[40] មាត្រា ៧៥១ កងាខណ្ឌទី១ វាក្យខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[41] មាត្រា ៧៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទេ។ កម្មសិទ្ធិករត្រង់ចំណុចនេះសំដៅដល់បុគ្គលដែលជាម្ចាស់កម្មសិទ្ធិលើវត្ថុគ្រោះថ្នាក់ រីឯអ្នកគ្រប់គ្រងសំដៅដល់បុគ្គលក្រៅពីកម្មសិទ្ធិករដែលបានកាន់កាប់វត្ថុគ្រោះថ្នាក់។ ដូចនេះហើយកាលណាលក្ខខណ្ឌទាំងនេះត្រូវបានបំពេញស្របតាមការកំណត់ នោះការទទួលខុសត្រូវនៃអំពើអនីត្យានុកូលសម្រាប់វត្ថុគ្រោះថ្នាក់ត្រូវបានកើតឡើង។

បន្ថែមពីនេះគោលការណ៍ក៏មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វដែរ គឺពុំចំណុះឱ្យគោលការណ៍ខុសនោះទេ ដូចនេះហើយដើម្បីឱ្យជនបង្កធ្វើការទទួលខុសត្រូវទៅលើការខូចខាតដែលបានបង្កឡើង គេមិនចាំបាច់ពិចារណាថាតើជនបង្កបានប្រព្រឹត្តនៅកំហុសណាមួយដែររឺទេ ដរាបណាមានការខូចខាតស្របទៅតាមលក្ខខណ្ឌបានកំណត់ នោះជនបង្កត្រូវធ្វើការទទួលខុសត្រូវ។

ម្យ៉ាងវិញទៀតនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ ក៏មានចែងអំពីការទទួលខុសត្រូវចំពោះឱសថដែលមានជាតិពុល ឬសារធាតុញៀន ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ។ ឱសថ គឺជាសារជាតិមួយមុខ ឬច្រើនមុខដែលមានប្រភេទជាអាទិ៍ពី ជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ រុក្ខជាតិ លាយផ្សំឡើងសម្រាប់៖

- ប្រើប្រាស់ក្នុងការបង្ការ ឬព្យាបាលជម្ងឺមនុស្ស សត្វ
- ការស្រាវជ្រាវវេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ
- កែប្រែ ឬទ្រទ្រង់មុខងារនៃសរីរាង្គ ។[42]

វត្ថុដែលច្បាប់ចាត់ទុកជាឱសថដែរមាន៖ សេរ៉ូម ឬវ៉ាក់សាំង, ឈាម ឬផលិតផលដែលបានមកពីឈាម, ឱសថបុរាណ, ផលិតផលដែលផ្សំឡើងដោយមានជាតិពុល ដែលមានក្នុងបញ្ជីកំណត់ដោយអនុក្រឹត្យ។[43] ជាតិពុលសំដៅលើឱសថ ឬសារជាតិ ឬសមាសធាតុនៃសារជាតិ ឬរុក្ខជាតិ ដែលអាចបង្កឱ្យគ្រោះថ្នាក់ដល់សុខភាព ឬឱ្យញៀនដល់មនុស្ស សត្វ ។[44]

ច្បាប់ស្តីពីវិសោធនកម្មច្បាបើស្តីពីការគ្រប់គ្រងឱសថនេះក៏មានចែងអំពីទោសបញ្ញត្តិចាប់ពីមាត្រា ១០ថ្មី ផងដែរ ដែលមានដូចជា៖

១. ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១,០០០,០០០រៀល(មួយលានរៀល) ដល់ ៥,០០០,០០០រៀល(ដប់លានរៀល) ចំពោះជនណាដែលបាន៖

42 មាត្រា ២ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ឆ្នាំ១៩៩៦

43 មាត្រា ៣ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ឆ្នាំ១៩៩៦

44 មាត្រា ៥ ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ឆ្នាំ១៩៩៦

- ផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសំអាងតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬតាមមធ្យោបាយផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខភិបាល

- ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌក្នុងការគ្រប់គ្រងថែរក្សាផលិតផលឱសថ

- បើក បិទ ឬ ប្តូរទីតាំងឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានលក់គ្រឿងសំអាង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

២. ផលិត ឬនាំចូល ឬនាំចេញ ឬស្តុកឱសថ វត្ថុធាតុដើមឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។

- បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថគ្រឹះស្ថាននាំចូល នាំចេញឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម អាហរ័ណ នីហរ័ណឱសថ

-នាំចូល ឬ នាំចេញ ផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ចែកចាយ តាំងលក់ ឬ លក់ផលិតផលឱសថ និងគ្រឿងសំអាងដែលគ្មាន ចុះលេខទិដ្ឋាការ ឬ បញ្ជីកាពីក្រសួងសុខាភិបាល

-លក់ឱសថខូចគុណភាព និងឱសថផុតកំណត់ប្រើប្រាស់

៣. ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០,០០០,០០០ រៀល (ដប់លានរៀល) ដល់២០,០០០,០០០ រៀល (ម្ភៃលានរៀល) ចំពោះជនណាដែលបាន៖

-បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសផលិតឱសថ

-នាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច សម្ភារះវេចខ្ចប់ម៉ាស៊ីន ឧបករណ៍សម្រាប់ផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ស្តុកវត្ថុធាតុដើម សម្ភារះវេចខ្ចប់ ម៉ាស៊ីនឧបករណ៍ផលិត ផលិតផលឱសថ ក្រៅពីគ្រឹះស្ថានអាជីវកម្មផលិតកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

៤. ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬ អាយុជីវិតមនុស្សសត្វ ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អាហរ័ណ នីហរ័ណ និងពាណិជ្ជកម្មឱសថជាបន្ទាន់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់

៥. ទោសទណ្ឌទាំងឡាយណា ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១,០០០,០០០រៀល (មួយលានរៀល) ដល់ ១០,០០០,០០០ រៀល (ដប់លានរៀល) ក្រសួងសុខាភិបាលមាន សិទ្ធិពិន័យអន្តរការណ៍ ។[45]

ជាក់ស្តែង នៅអំឡុងឆ្នាំ២០២០ កន្លងមក ឪពុកម្តាយ ១៥គ្រួសារ បានដាក់ពាក្យបណ្តឹងលើម្ចាស់ផលិតម្សៅទឹកដោះគោម៉ាក Nutrilatt ទៅកាន់ក្រសួងសុខាភិបាល និងក្រសួងពាណិជ្ជកម្ម ដោយសារតែកូនរបស់ពួកគាត់ មានអាការស្លេកស្លាំង ធ្លាក់ខ្លួនឈឺ ក្រោយប្រើប្រាស់ផលិតផលនេះ ។ ឆ្លើយតបទៅនឹងពាក្យបណ្តឹង អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម(ក.ប.ប) បានយកសំណាកទឹកដោះគោទៅមន្ទីរពិសោធន៍ឯករាជ្យមួយនៅប្រទេសសិង្ហបុរី ហើយលទ្ធផលបង្ហាញថា ម្សៅទឹកដោះគោ ពិតជាមានសារធាតុដែកទាប ដែលគ្រោះថ្នាក់ខ្លាំងដល់សុខភាពទារក នេះបើយោងតាមផេកហ្វេសបុកផ្លូវការរបស់ ក.ប.ប ។[46] បន្ទាប់មកនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ តុលាការរាជធានីភ្នំពេញ ប្រកាសសាលក្រមផ្តន្ទាទោស នាយិការ នៃក្រុមហ៊ុន Nutrilatt Master LM Co. LTD ដាក់គុកកំណត់១០ខែ និងពិន័យជាប្រាក់ចំនួន ៨លានរៀល (ប្រមាណ ២.០០០$) សម្រាប់ដាក់ចូលក្នុងថវិកាជាតិ ជាប់ពាក់ព័ន្ធនឹងការចែកចាយ និងលក់ផលិតផលម្សៅទឹកដោះគោ ដែលគ្មានគុណភាព និងមានកម្រិតសារធាតុដែក និងសង្កសីយ៉ាងទាបបំផុត ដែលធ្វើអោយប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់ សុខភាពរបស់ទារក និងកុមារតូច នៅទូរទាំងប្រទេស ដែលបានប្រើប្រាស់ នូវផលិតផល របស់ក្រុមហ៊ុនខាងលើនេះ ។ តុលាការរាជធានីភ្នំពេញ ក៏បានបង្គាប់ឱ្យស្ត្រីជាប់ចោទ ត្រូវសងថ្លៃជម្ងឺចិត្ត ពីចំនួន១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ទៅ ២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ដល់ភាគីដើមបណ្តឹង(ភាគីរដ្ឋប្បវេណី) ចំនួន២២នាក់ ដែលជាមាតាបិតា របស់កុមាររងគ្រោះ ក្នុងម្នាក់ៗ តែបើកផ្លូវឱ្យភាគីទាំងពីរ មានសិទ្ធិប្តឹងតវ៉ា ទៅកាន់តុលាការឧទ្ធរណ៍ តាមផ្លូវច្បាប់ ។[47]ចំពោះលក្ខខណ្ឌអនុវត្តសម្រាប់គោលការណ៍មានលក្ខណៈតឹងរឹងចំពោះជនបង្កដែលពិបាកក្នុងការរួចផុតពីការទទួលខុសត្រូវចំពោះអំពើបង្កជាការខូចខាត ។ យ៉ាងណាក្តីក៏ពុំមែនមានន័យថាគ្មានផ្លូវដែលអាចឱ្យជនបង្ករួចផុតពីការទទួលខុសត្រូវឡើយ។ ជាក់ស្តែងក្នុងក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិអំពីករណីលើកលែងដែលជាអញ្ញត្តកម្ម ដើម្បីអនុញ្ញាតឱ្យជនបង្កអាចមានឱកាសរួច

[45] មាត្រា ១០ ច្បាប់ស្តីពីសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ ឆ្នាំ២០០៧

[46] សេចក្តីប្រកាសព័ត៌មានរបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ "បណ្តឹងឪពុកម្តាយ ១៥គ្រួសារ លើក្រុមហ៊ុនទឹកដោះគោ Nutrilatt"

[47] Dap-new "ផ្តន្ទាទោស នាយិកាក្រុមហ៊ុន Nutrilatt Master LM Co.LTD ដាក់គុក១០ខែ និងបង្គាប់ឱ្យសងប្រាក់ជិត ៤០ម៉ឺនដុល្លារ ពាក់ព័ន្ធលក់ម្សៅទឹកដោះគោគ្មានគុណភាព និងប៉ះពាល់សុខភាពទារក និងកុមារនៅកម្ពុជា" ផ្សាយដោយ DR103 ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ គេហទំព័រ https://dap-news.com/national/2022/04/03/233995/ ថ្ងៃចូលគេហទំព័រ ០១ ឧសភា ឆ្នាំ២០២៣

ផុតពីការទទួលខុសត្រូវ ។[48] គេបានកំណត់ថា កាលណាការខូចខាតបណ្ដាលមកពីករណីប្រធានសក្តិ នោះបង្កពុំចាំបាច់ត្រូវធ្វើការទទួលខុសត្រូវនោះទេ។ ដូចនេះករណីជនបង្កបានបង្កការខូចខាតណាមួយដែលមានស្ថានភាពស្របទៅតាមអត្ថន័យនៃការកំណត់នេះ ជនបង្កពុំចាំបាច់ធ្វើការទទួលខុសត្រូវចំពោះការខូចខាតនោះទេ ។ ករណីមួយផ្សេងទៀតគឺការខូចខាតកើតឡើងក្នុងស្ថានភាពដែលគ្មានវិការៈ ដោយជនបង្កបានគ្រប់គ្រងវត្ថុគ្រោះថ្នាក់ដោយគ្មានវិការៈ ហើយការខូចខាតបណ្ដាលមកពីជនរងគ្រោះ ឬតតិយជនទៅវិញដោយគ្មានវិការៈ ។ ត្រង់ចំណុចនេះសំដៅដល់ស្ថានភាពមួយដែលជនបង្កបានគ្រប់គ្រងវត្ថុគ្រោះថ្នាក់បានជាធម្មតា ហើយគ្មានចំណុចប្រក្រតីណាមួយបានកើតឡើងទេ ដែលជាដើមហេតុនៃការបង្កការខូចខាត ។ ផ្ទុយទៅវិញជនរងគ្រោះ ឬតតិយជនទៅវិញទេដែលជាអ្នកបង្កកំហុសជាដើមហេតុនៃការខូចខាត នោះជនបង្កអាចរួចផុតពីការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ។

បញ្ជាក់បន្ថែមទៀតថា ចំណុចនេះគឺសង្កត់ធ្ងន់ទៅលើកំហុសរបស់ជនរងគ្រោះជាធំប្រសិនជាក្នុងករណីដែលជនបង្កបានគ្រប់គ្រងវត្ថុគ្រោះថ្នាក់ដោយគ្មានវិការៈ តែយ៉ាងណាក្តីការខូចខាតនោះបង្កឡើងដោយវត្ថុគ្រោះថ្នាក់ហើយថែមទាំងគ្មានកំហុសពីសំណាក់ជនរងគ្រោះ ឬតតិយជននោះប្រាកដណាស់គ្មានទេការលើកលែងចំពោះជនបង្ក។ ដូចបានរៀបរាប់នៅខាងលើគោលការណ៍នេះមិនចំណុះឱ្យកំហុសរបស់ជនបង្កនោះទេ ដូចនេះហើយមិនថាជនបង្កបានបង្កកំហុសឬទេ ប្រសិនបើការខូចខាតបានបង្កឡើងដោយវត្ថុគ្រោះថ្នាក់ស្របតាមលក្ខខណ្ឌអនុវត្ត ហើយជនរងគ្រោះ ឬតតិយជនមិនបានបង្កកំហុសណាមួយទៀត នោះការទទួលខុសត្រូវនឹងកើតមានឡើងចំពោះការខូចខាតរបស់ជនរងគ្រោះ ។

## ២.២.៣. ការចូលរួមរបស់វត្ថុក្នុងពេលកើតមានព្យសនកម្ម

កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងទទួលខុសត្រូវត្រឹមតែលើការបង្កព្យសនកម្ម ទាល់តែវត្ថុនោះចូលរួមក្នុងការបង្កើតឱ្យមានព្យសនកម្ម ហើយជនរងគ្រោះត្រូវបង្ហាញអំពីទំនាក់ទំនងហេតុទៅផលនៃការចូលរួមរបស់វត្ថុ និងព្យសនកម្ម។ ទំនាក់ទំនងភស្តុតាងនៃការចូលរួមរបស់វត្ថុនេះវាចាំបាច់ត្រូវតែបែងចែកទៅតាមការមាន ឬគ្មានការប៉ះពាល់ជាសម្ភារៈនៃវត្ថុជាមួយជនរងគ្រោះ (ឬជាមួយទ្រព្យសម្បត្តិ ដែលធ្វើឱ្យខូចខាតជាកម្មសិទ្ធិរបស់ជនរងគ្រោះ) ។ គ្រោះថ្នាក់ ដែលកើតមានឡើងដោយគ្មានការប៉ះពាល់ជាសម្ភារៈរវាងវត្ថុនិងបុគ្គលដែលរងរបួស (ឬវត្ថុធ្វើឱ្យខូចខាត) វាជាបន្ទុករបស់ជនរងគ្រោះដែលត្រូវបង្ហាញថាមានការចូលរួមរបស់វត្ថុជាមួយនឹងមុខងារ ដែលបង្ក

[48] មាត្រា ៧៥១ កថាខណ្ឌទី១ វាក្យខ័ណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឡើងពីវត្ថុនេះ ។ បើមានការប៉ះពាល់នាំឱ្យមានការខូចខាតជាមួយវត្ថុ ជនរងគ្រោះត្រូវបង្ហាញភស្តុតាងថាមានការចូលរួមរបស់វត្ថុប៉ុណ្ណោះ[49] ។

ឧទាហរណ៍៖ នៅលើផ្លូវបំបែកជាបួនមួយកន្លែង ដែលនៅកន្លែងនោះស្រាប់តែមានឡានមួយគ្រឿងស្រាប់តែបើកមករាំងផ្លូវភ្លាមៗខាងមុខអ្នកបើកម៉ូតូម្នាក់ ដើម្បីចៀសវាងការប៉ះឡាន អ្នកបើកម៉ូតូម្នាក់នោះត្រូវតែងាកចង្កូតចេញភ្លាមៗបណ្តាលឱ្យរងរបួស ។

[49] ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៣០

# ជំពូកទី៣

# ជំពូកទី៣
# ការរួចផុតពីការទទួលខុសត្រូវ

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងឯកសារច្បាប់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការកំណត់អំពីការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងទៅលើអំពើនៃវត្ថុរបស់ខ្លួន ហើយបើសង្កេតទៅមើលក្នុងច្បាប់ទាំងនោះ ក៏បានឃើញថា ក្រមរដ្ឋប្បវេណី និងច្បាប់ទាំងនោះ ក៏បានបញ្ញត្តិចំពោះករណី ដែលអាចធ្វើឱ្យកម្មសិទ្ធិករនៃវត្ថុ និងអ្នកគ្រប់គ្រងវត្ថុ អាចរួចផុតពីការទទួលខុសត្រូវផងដែ

យោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ កាលណាអំពើនៃវត្ថុបង្កើតឱ្យមានព្យសនកម្មដល់តតិយជន កម្មសិទ្ធិករនៃវត្ថុត្រូវធ្វើការទទួលខុសត្រូវលើព្យសនកម្មទាំងអស់នោះ ។ កម្មសិទ្ធិករត្រូវតែមានកាតព្វកិច្ចទទួលខុសត្រូវចំពោះអំពើនៃវត្ថុរបស់ខ្លួន កាលបើកើតមានព្យសនកម្ម ប៉ុន្តែកម្មសិទ្ធិករអាចរួចផុតពីការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាននេះបានដោយមូលហេតុ ដូចជាៈ

- កិច្ចការពារធម្មានុរូប និងស្ថានភាពចាំបាច់
- ករណីប្រធានសក្តិ
- កំហុសរបស់ជនរងគ្រោះ
- អំពើរបស់តតិយជន
- និងករណីចលនវត្ថុបម្លាស់ទី

## ៣.១. កិច្ចការពារធម្មានុរូប និងស្ថានភាពចាំបាច់

-ការការពារធម្មនុរូប គឺសំដៅទៅលើអំពើរំលោភដែលពុំអាចចៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និងអំពើរំលោភនោះ ស្ថិត ជិតគ្នា និងមានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។[50] ដើម្បីអាចអនុវត្តនូវបញ្ញត្តិនេះបាន លុះត្រាស្ថានភាពនៃការបំពានសិទ្ធិនោះស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងនិយមន័យ ទើបអាចចាត់ទុកជាការការពារជាធម្មានុរូបបាន។ ជាក់ស្តែងអំពើរំលោភនោះ ត្រូវតែជាអំពើរំលោភ ដែលពុំអាចចៀសវាងបាន មានន័យថានៅក្នុងស្ថានភាពនៃការប្រឆាំងនោះត្រូវជាសកម្មភាព ដែលជនបង្កនោះមិនអាចជម្នះបានឧបសគ្គដែលខ្លួនប្រឈមដោយគ្មានជម្រើសអ្វីផ្សេងក្រៅពីការប្រឆាំងតបទៅវិញឡើយ ដែលជាមូលហេតុនាំឱ្យមាននូវការខូចខាត។

[50] មាត្រា ៧៥៥ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រៅពីនេះមានការបំពានដោយមិនត្រឹមត្រូវ ដែលការបំពានដោយមិនត្រឹមត្រូវនេះ សំដៅដល់ការបំពានដែលបានធ្វើឡើងទៅលើរូបកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួនឬអ្នកដទៃ។ ដូចនេះហើយ ប្រសិនបើការរំលោភ ឬការប្រឆាំងតបមួយមានគោលបំណងតែដើម្បីការពាររូបកាយ ឬទ្រព្យសម្បត្តិពីការបំពានដែលមិនត្រឹមត្រូវនាំឱ្យអំពើនោះគឺអាចទុកជាការការពារធម្មានុរូប។ មួយផ្សេងទៀត ការប្រឆាំងនឹងឧបសគ្គគឺស្ថិតនៅជិតគ្នា ដោយការប្រឆាំងតបភ្លាមចំពោះឧបសគ្គ ដោយមិនមែនពេលដែលឧបសគ្គចប់សព្វគ្រប់ហើយទើបធ្វើការប្រឆាំងទៅវិញឡើយ។ ចុងក្រោយគឺជាការកំណត់អំពីតុល្យភាពរវាងមធ្យោបាយការពារ និងឧបសគ្គដែលប្រឈមគឺត្រូវមានភាពប្រហាក់ប្រហែលគ្នា បើកាលណាការប្រឆាំងតបនឹងឧបសគ្គដែលប្រឈមមានទំហំធំហួសហេតុនោះ គឺពុំអាចពិចារណាថាជាការការពារធម្មានុរូបឡើយ។ ដូចេះប្រសិនបើលក្ខខណ្ឌទាំងនេះត្រូវបានបំពេញព្រមគ្នា ហើយអំពើបំពាននោះមិនចាំបាច់ទទួលខុសត្រូវដោយអំពើនីត្យានុកូលឡើយ ដោយចាំទុកជាការការពារធម្មានុរូប។

អំពើការពារជាធម្មានុរូប ពុំត្រូវបានចាត់ទុកជាអំពើបំពានដោយផ្ទុយច្បាប់ឡើយ ដោយហេតុថាបុគ្គលដែលបានប្រព្រឹត្តអំពើនេះ ត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តអំពើរំលោភបំពានដែលមិនអាចចៀសវាងបានដើម្បីការពារផលប្រយោជន៍ ( រូបកាយ ទ្រព្យសម្បត្តិ ) របស់ខ្លួន ឬអ្នកដទៃ ដោយតទល់ត្រឹមតែចំពោះអ្នកដែលបានរំលោភបំពានដោយមិនត្រឹមត្រូវ គឺថែមទាំងតតិយជនផ្សេងទៀតផងដែរ។

ការការពារជាធម្មានុរូបត្រូវស្របនឹងលក្ខខណ្ឌដូចខាងក្រោម៖

១. អំពើបំពានដោយមិនត្រឹមត្រូវ

២. ដើម្បីការពាររូបកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬរបស់អ្នកដទៃ

៣. អំពើដែលមិនអាចជៀសវាងបាន

៤. ពេលវេលានៃអំពើបំពាន និង ពេលវេលានៃអំពើដេលធ្វើឱ្យគេរងគ្រោះនោះជិតគ្នា

៥. មានតុល្យភាពរវាងវិធីការពារខ្លួន និង កម្រិតនៃអំពើបំពាន។[51]

-ស្ថានភាពចាំបាច់ គឺសំដៅទៅលើអំពើរំលោភបំពានដែលមិនអាចចៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ:អច្ចាសន្ន ហើយដែស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និង កម្រិត គ្រោះថ្នាក់នោះ ។[52]

[51] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ ទំព័រទី៩៨

[52] មាត្រា ៧៥៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្ថានភាពចាំបាច់ ក៏ជាលក្ខណ្ឌដែលនាំឱ្យមានការមិនទទួលខុសត្រូវចំពោះអំពើនីត្យានុកូលផងដែរដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ ស្ថានភាពនេះសំដៅទៅដល់អំពើរំលោភក្នុងភាពចាំបាច់ជាអំពើរំលោភនឹងគ្រោះថ្នាក់ ឬអច្ចាសន្ន។នៅពេលដែលមានគ្រោះថ្នាក់ ឬរៀបនឹងមានគ្រោះថ្នាក់ ការប្រព្រឹត្តអំពើរំលោភលើទ្រព្យសម្បត្តិអ្នកដទៃដែលមិនអាចជៀសវាងបានគួរត្រូវបានលើកលែងពីការទទួលខុសត្រូវក្នុងការខូចខាត ប៉ុន្តែប្រសិនបើគ្រោះថ្នាក់នោះវាកើតឡើងដោយសារតែការមិនប្រុងប្រយ័ត្នរបស់អ្នកប្រព្រឹត្តអំពើរំលោភ អ្នកប្រព្រឹត្តនោះត្រូវទទួលខុសត្រូវដែលវាជារឿងសមហេតុផល។ តាមន័យច្បាប់បានទទួលយ៉ាងច្បាស់នូវស្ថានភាពចាំបាច់នេះជាមធ្យោបាយដែលនាំឱ្យអ្នកបានប្រព្រឹត្តរំលោភអាចរួចផុតពីការទទួលខុសត្រូវ។ ប៉ុន្តែដើម្បីឱ្យស្ថានភាពនេះមានអនុភាពស្របតាមផ្លូវច្បាប់ ដរាបណាបានគោរពនូវលក្ខខណ្ឌមួយចំនួនជាមុនសិន ដូចជា៖

**ទី១** មានគ្រោះថ្នាក់ ឬសច្ចាសន្នដែលស្ថានភាពគ្រោះថ្នាក់នោះសំដៅដល់ហេតុការគ្រោះថ្នាក់ចៃដន្យដែលកំពុងតែកើត។ ចំណែកឯអច្ចាសន្នវិញសំដៅដល់គ្រោះថ្នាក់ដែលមិនទាន់កើតឡើង ប៉ុន្តែរៀបនឹងកើតឡើង។ ដូចនេះការប្រព្រឹត្តអំពើរំលោភ គឺមានគោលដៅដើម្បីបញ្ចៀសស្ថានភាពគ្រោះថ្នាក់ ឬអច្ចាសន្នដែលនាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ។ ផ្ទុយទៅវិញប្រសិនបើគ្មានស្ថានភាពគ្រោះថ្នាក់ ឬអច្ចាសន្នទេ ក៏គ្មានដែរស្ថានភាពចាំបាច់ក្នុងការប្រព្រឹត្តអំពើរំលោភដែរ។

**ទី២** អំពើរំលោភមិនអាចចៀសវាងបាន ដែលក្នុងស្ថានភាពនោះអំពើរំលោភធ្វើឡើងដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ពីស្ថានភាពគ្រោះថ្នាក់ ឬអច្ចាសន្នណាមួយ អ្នកប្រព្រឹត្តអំពើរំលោភពុំមានជម្រើសណាមួយក្រៅពីប្រព្រឹត្តអំពើរំលោភដែលនាំឱ្យមានការខូចខាតឡើយ។ ដូចគ្នានឹងស្ថានភាពនៃការការពារធម្មានុរូបដែរ ប្រសិនបើមានជម្រើសផ្សេងក្រៅពីការរំលោភបំពានដល់អ្នកដទៃហើយនៅតែប្រព្រឹត្តនាំឱ្យអំពោះនោះមិនត្រូវចាត់ទុកថាស្ថិតក្នុងស្ថានភាពចាំបាច់ឡើយ។

**ទី៣** តុល្យភាពរវាងអំពើរំលោភ និងអំពើបំពាន នៅក្នុងស្ថានភាពចាំបាច់គឺជាការប្រព្រឹត្តអំពើរំលោភប្រយោជន៍របស់អ្នកដទៃក្នុងគោលដៅបញ្ចៀសកុំឱ្យកើតឡើង ឬបន្ថយនូវកម្រិតនៃគ្រោះថ្នាក់។ វាគ្មានប្រយោជន៍ទេប្រសិនបើប្រយោជន៍ដែលត្រូវការពារ មានលក្ខណៈតូចជាងប្រយោជន៍ដែលត្រូវប្រព្រឹត្តរំលោភក្នុងហេតុផលស្ថានភាពចាំបាច់។ ដូចនេះហើយដើម្បីឱ្យភាពសមស្របក្នុងការប្រព្រឹត្តអំពើរំលោភដែលស្ថិតក្នុងស្ថានភាពចាំបាច់ ប្រយោជន៍ដែលត្រូវរំលោភនិងប្រយោជន៍ដែលត្រូវការពារត្រូវមានតុល្យភាពរវាងគ្នា។

ការបំពានដោយស្ថានភាពចាំបាច់ត្រូវស្របនឹងលក្ខខណ្ឌដូចខាងក្រោម៖

១. មហន្តរាយបច្ចុប្បន្ន ឬសច្ចាសន្ន

២. ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬរបស់អ្នកដទៃ

៣. អំពើដែលធ្វើឱ្យគេរងគ្រោះដោយមិនអាចជៀសវាងបាន

៤. ពេលវេលានៃអំពើបំពាន និង ពេលវេលានៃគ្រោះថ្នាក់នោះជិតគ្នា

៥. មានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃគ្រោះថ្នាក់។[53]

## ៣.២. ករណីប្រធានសក្តិ

ប្រធានសក្តិ សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍ ដែលកើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុបកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ ។[54]

យោងតាមសន្ធានុក្រម ផ្នែករដ្ឋប្បវេណី ការខូចខាតបណ្តាលមកពីករណីប្រធានសក្តិ អ្នកប្រព្រឹត្តមិនត្រូវបានទទួលខុសត្រូវទេ ពីព្រោះករណីប្រធានសក្តិ ជាព្រឹត្តិការណ៍កើតឡើងក្រៅឆន្ទៈរបស់ភាគីមិនអាចដឹងមុន ហើយមិនអាចជម្នះបាន ។ ជាការបកស្រាយប្រធានសក្តិអាចជាព្រឹត្តិការណ៍ដែលកើតពីធម្មជាតិ ឬព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីធម្មជាតិ ដរាបណាព្រឹត្តិការណ៍នោះបំពេញលក្ខខណ្ឌបីគឺ៖ ព្រឹត្តការណ៍នោះកើតឡើងក្រៅឆន្ទៈរបស់ភាគី, ព្រឹត្តិការណ៍នោះមិនអាចប៉ាន់ស្មានជាមុនបាន និង ព្រឹត្តការណ៍នោះមិនអាចជម្នះបាន មិនអាចគ្រប់គ្រងបាន[55] ។

១. ព្រឹត្តិការណ៍នោះកើតឡើងក្រៅឆន្ទៈរបស់ភាគី ។ ភាគីដែលរងគ្រោះដោយសារព្រឹត្តិការណ៍នោះមិនបានពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងមូលហេតុនៃការកើតឡើងនៃព្រឹត្តិការណ៍នោះ ។ មានន័យថាព្រឹត្តការណ៍ប្រធានសក្តិនោះ គឺកើតឡើងដោយគ្មានទាំងកំហុសកម្មសិទ្ធិករ និងជនរងគ្រោះ ។

២. ព្រឹត្តិការណ៍នោះមិនអាចប៉ាន់ស្មានជាមុនបានឡើយ ។ ព្រឹត្តិការណ៍មិនអាចប៉ាន់ស្មានជាមុន គឺព្យសនកម្មកើតឡើងដោយប្រធានសក្តិ ហើយព្រឹត្តិការណ៍នោះ មិនអាចធ្វើការប៉ាន់ស្មាន់ជាមុន ថានឹងកើតមានព្រឹត្តការណ៍នៃប្រធានសក្តិដែលបង្កជាព្យសនកម្មនោះកើតឡើងនោះទេ ។ បើព្រឹត្តិការណ៍មួយអាចត្រូវបានប៉ាន់ស្មានបាន ព្រឹត្តិការណ៍នោះមិនមែនជាប្រធានសក្តិឡើយ ។

---

[53] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ ទំព័រ៩៩

[54] ប្រការ ៣ កថាខណ្ឌទី៣ ប្រកាស ស្តីពីការគ្រប់គ្រងបំណុលពន្ធដា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០

[55] [55] Nop Kanharith "ប្រធានសក្តិ" គេហទំព័រ៖

https://nopkanharith.com/2022/06/21/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%92%E1%9E%B6%E1%9E%93%E1%9E%9F%E1%9E%80%E1%9F%92%E1%9E%8F%E1%9E%B7/ ថ្ងៃចូលគេហទំព័រ ១០ ឧសភា ឆ្នាំ២០២៣

៣. ព្រឹត្តិការណ៍នោះមិនអាចជម្នះបាន មិនអាចគ្រប់គ្រងបាន គឺ ព្រឹត្តិការណ៍ដែលបានកើតឡើងហើយមិនអាចធ្វើការជម្នះបាន ទោះបីប្រើប្រាស់គ្រប់មធ្យោបាយដើម្បីរារាំងយ៉ាងណាក៏ដោយ ក៏ព្រឹត្តិការណ៍នៅតែកើតមានឡើង ។ បើព្រឹត្តិការណ៍មួយអាចត្រូវបានគ្រប់គ្រងបានគឺមិនមែនជាករណីប្រធានសក្តិឡើយ ។

ជាក់ស្តែង ជាទូទៅក្នុងករណីខ្យល់ព្យុះ ឬខ្យល់បន្ត្រាក់ រន្ទះបាញ់ ដែលកើតឡើងភ្លាមៗ ដែលមិនអាចធ្វើការព្យាករណ៍បាន ដែលបានបណ្តាលឱ្យមានព្យសនកម្មកើតឡើងលើជនរងគ្រោះ នោះក្នុងករណីនេះកម្មសិទ្ធិករមិនទទួលខុសត្រូវរដ្ឋប្បវេណីនោះទេ ។ ឧទាហរណ៍ ករណីមានខ្យល់ព្យុះបណ្តាលឱ្យដើមឈើរលើងឫស ហើយរលំដួលកាត់ផ្លូវរថយន្តដែលកំពុងធ្វើដំណើរ ហើយបង្កឱ្យខូចខាតរថយន្តនោះ កម្មសិទ្ធិករនៃដើមឈើនោះរួចផុតពីការទទួលខុសត្រូវ ។

## ៣.៣. កំហុសរបស់ជនរងគ្រោះ

បុគ្គលដែលធ្វើឱ្យខូចខាតដល់អ្នកដទៃ តែមិនត្រូវទទួលខុសត្រូវ ប្រសិនបើការខូចខាតនោះបណ្តាលមកពីជនរងគ្រោះ ។ កាលណាអំពើបំពាន ឬព្យសនកម្មបានកើតឡើងដោយសារកំហុសរបស់ជនរងគ្រោះទាំងស្រុងរបស់ជនរងគ្រោះ ហើយគ្មានកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងវត្ថុ នោះកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងមិនទទួលខុសត្រូវលើសំណងនៃការខូចខាតនោះទេ។ កំហុសជនរងគ្រោះ អាចកើតឡើងក្នុងពីរករណី គឺ កំហុសជនរងគ្រោះក្នុងករណីអចលនវត្ថុ និងករណីចលនវត្ថុបំពេញមុខងារអកម្ម ។

### ៣.៣.១. កំហុសរបស់ជនរងគ្រោះក្នុងករណីអចលនវត្ថុ

ក្នុងករណីនេះ គឺសម្តៅដល់ការរួចផុតពីការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងនៃសំណង់ អគារនៅពេលកើតមានព្យសនកម្ម ។ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងនៃសំណង់ អគារអាចរួចផុតពីការទទួលខុសត្រូវបានករណីព្យសនកម្មកើតឡើងមិនមែនជាកំហុសរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង ប៉ុន្តែព្យសនកម្មបណ្តាលមកពីកំហុសរបស់ជនរងគ្រោះផ្ទាល់ខ្លួន ។ ជាក់ស្តែង ករណីសំណង់ អគារចាស់ៗ ឬបែកបាក់ ត្រូវបានទុកចោល និងមានដាក់ស្លាកសញ្ញាហាមមិនឱ្យចូលទៅក្នុងសំណង់ អគារនោះ និងមានរនាំងដាក់ហាមមិនឱ្យចូល ប៉ុន្តែជនរងគ្រោះនៅតែជម្នះចូល ហើយបានបង្កឱ្យមានព្យសនកម្មមកលើខ្លួនដោយករណីណាមួយ ដូចជាបាក់ថ្មធ្លាក់មកពីលើដែលបណ្តាលឱ្យរងរបួសជាដើម ។ ក្នុងករណីដូចនេះ កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង មិនទទួលខុសត្រូវលើព្យសនកម្មដែលបានបង្កដោយសំណាង អគាររបស់ខ្លួននោះទេ ព្រោះកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង បានប្រើគ្រប់មធ្យោបាយដើម្បីមិនឱ្យកើតមានព្យសនកម្មលើអ្នកដទៃ ដូចជាការដាក់បំរាមហាមមិនឱ្យចូលក្នុងសំណង់អគារដែលបែកបាក់ និងមានការដាក់រនាំងហាមមិនឱ្យចូល ជាដើម ប៉ុន្តែព្យនកម្មគឺកើតឡើងពីកំហុសជនរងគ្រោះដែលបានជម្នះចូលទៅក្នុងអគារដែលគេហាមឃាត់នោះទៅវិញ ។

### ៣.៣.២. ករណីចលនវត្ថុបំពេញមុខងារអកម្ម

កាលបើវត្ថុបានបំពេញមុខងារត្រឹមត្រូវតែអកម្មហើយនៅពេលមានគ្រោះថ្នាក់វត្ថុនោះ មានស្ថានភាពធម្មតា ឬត្រឹមត្រូវហើយនោះ ឆ្មាំ (កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង់ថែរក្សាវត្ថុ )រួចពីការទទួលខុសត្រូវ ។ ផ្ទុយមកវិញបើវត្ថុដែលបានប្រើមិនធម្មតា (ឧទាហរណ៍៖ បើផុងសម្រាមត្រូវបានទុកចោលកណ្តាលច្រកចង្អៀតហើយងងឹត) ឆ្មាំត្រូវបានចាត់ទុកថាមានការទទួលខុសត្រូវ (វត្ថុត្រូវបានសន្មតថាជាមូលហេតុបង្កឱ្យមានការអន្តរាយ) ។[56] កាលណាវត្ថុអកម្មត្រូវបានទុកដាក់មិនបានត្រឹមត្រូវ នោះវត្ថុអកម្មនឹងក្លាយជាវត្ថុអកម្មខុសច្បាប់ ដោយបង្កឱ្យមានការខូចខាតកើតឡើង។

## ៣.៤. អំពើតតិយជន

អំពើជាកំហុសរបស់តតិយជនមានពីរករណី គឺ៖ អំពើជាកំហុសទាំងស្រុងរបស់តតិយជន និង អំពើជាកំហុសមួយចំណែករបស់តតិយជន។

- កាលណាព្យសនកម្មកើតឡើងដោយអំពើជាកំហុសទាំងស្រុងរបស់តតិយជន ឆ្មាំវត្ថុ (កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង់ថែរក្សាវត្ថុ) អាចរួចពីការទទួលខុសត្រូវពីសំណងនៃការខូចខាត ។[57] មានន័យថាបើការខូចខាតត្រូវបានកើតឡើងដោយសារតែកំហុសតតិយជនទាំងស្រុង ហើយកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងមិនមានកំហុសក្នុងការបង្កើតឱ្យមានព្យសកម្មទៅលើជនរងគ្រោះទេ ។ ក្នុងករណីនេះកម្មសិទ្ធិករនៃវត្ថុ ឬអ្នកគ្រប់គ្រងអាចរួចផុតពីការទទួលខុសត្រូវលើសំណងនៃការខូចខាត ដោយគ្រាន់តែរកភស្តុតាងបញ្ជាក់ថាព្យសនកម្មកើតឡើងមិនមែនជាកំហុសរបស់ខ្លួន ប៉ុន្តែជាកំហុសរបស់តតិយជន ។
- កាលបើកំហុសរបស់តតិយជន មិនមែនជាមូលហេតុតែមួយនៃការខូចខាតតែកំហុសនោះវាបានចូលរួមទៅនឹងការកើតមានការខូចខាត នោះវានាំឱ្យមានការបែងចែកការទទួលខុសត្រូវ ហើយភាគនៃការជួសជុលអន្តរាយជាបន្ទុករបស់ឆ្មាំវត្ថុ ។[58] មានន័យថា បើព្យសនកម្មកើតឡើងមិនមែនជាកំហុសតតិយជនទាំងស្រុង ប៉ុន្តែមានការចូលរួមពីកំហុសរបស់កម្មសិទ្ធិករដែរនោះ ដូច្នេះកម្មសិទ្ធិករ និងតតិយជននោះត្រូវរួមគ្នាជួសជុលព្យសនកម្មដល់ជនរងគ្រោះ ។

[56] ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៤៣

[57] ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៤៣

[58] ញឹក វុទ្ធី នីតិកាតព្វកិច្ច ភាគ២ ទំព័រ៤៣

## ៣.៥. ករណីចលនវត្ថុបន្លាស់ទី

ចលនវត្ថុបន្លាស់ទីនេះ គឺសម្តៅដល់ចលនវត្ថុដែលជាយានយន្តគ្រប់ប្រភេទ ដូចជា យានយន្តផ្លូវដែក យានយន្តផ្លូវថ្នល់ យានយន្តផ្លូវអាកាស ឬអាកាសចរណ៍ និងយានយន្តផ្លូវទឹក ឬនាវាចរណ៍ ។ ចំពោះករណីចលនវត្ថុបន្លាស់ទីខាងលើនេះ គឺផ្តោតសំខាន់ទៅលើករណីយានយន្តផ្លូវថ្នល់ ដែលឃើញកើតមានច្រើននៅក្នុងសង្គម ។ យានយន្តផ្លូវថ្នល់មានដូចជា៖ រថយន្តគ្រប់ប្រភេទ ម៉ូតូគ្រប់ប្រភេទ ម៉ូតូកង់បី និងរ៉ម៉ក ជាដើម ។

បើការខូចខាតកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ជនរងគ្រោះ ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។ ជីវភាពក្នុងសង្គមកាន់តែមានការស្មុកស្មាញទៅៗ ហើយកាន់តែមានកម្រិតខ្ពស់ទៅៗ ហេតុនេះហើយមានករណីជាច្រើនដែលការខូចខាតកើតឡើងដោយសារបុគ្គលច្រើននាក់ (ការខូចខាតដោយសារមូលហេតុចម្រុះ) ។ ក្នុងករណីនេះ មានភាពពិបាកនឹងកំណត់អ្នកដែលបង្កើតបញ្ហានោះណាស់ ។ ដូច្នេះហើយ ចំណុចនេះមានគោលបំណងជួយសង្គ្រោះជនរងគ្រោះ ដោយបន្ថយនូវភាពពិបាកក្នុងការបញ្ជាក់របស់ជនរងគ្រោះ តាមរយៈការចាត់ទុក ឬការសន្មតនូវទំនាក់ទំនងហេតុ និងផល រវាងអ្នកធ្វើអំពើរួមទាំងអស់ និងការខូចខាត ដែលបានកើតឡើងដោយយកភាពរួមគ្នា (ពាក់ព័ន្ធគ្នា) មកធ្វើជាលក្ខខណ្ឌ ។ ប្រសិន បើអ្នកប្រព្រឹត្តអំពើនីមួយៗ បានបញ្ជាក់អំពើភាគនៃអំពើភាគនៃអំពើដែលខ្លួនបាន បង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតតាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក។ បើជនណាម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតបាន តាមសមាមាត្រដែលជនម្នាក់ៗបានបង្កឡើង ។[59]

ក្នុងករណីដែលមានព្យសនកម្មកើតឡើង ដោយមានការចូលរួមពីវត្ថុច្រើននោះ បើកម្មសិទ្ធិករណាដែលគ្មានកំហុសក្នុងការបង្កើតឱ្យមានព្យសនកម្មកើតឡើងចំពោះជនរងគ្រោះនោះ កម្មសិទ្ធិករនោះមិនត្រូវទទួលខុសត្រូវលើព្យសនកម្មឡើយ ដោយគ្រាន់តែបង្ហាញភស្តុតាងថាខ្លួនគ្មានកំហុសក្នុងការបង្កើតឱ្យមានព្យសនកម្ម ។ ប៉ុន្តែបើក្នុងករណីព្យសនកម្មកើតឡើងដោយមានការចូលរួមពីវត្ថុច្រើន ហើយកម្មសិទ្ធិករទាំងអស់ សុទ្ធតែមានកំហុសក្នុងការបង្កើតឱ្យមានព្យសនកម្មដល់ជនរងគ្រោះនោះ កម្មសិទ្ធិករទាំងអស់នោះត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតរួមគ្នា ។

[59] មាត្រា ៧៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍៖ រថយន្តចំនួន ០២គ្រឿង រថយន្តA និងរថយន្តB កំពុងឈប់បន្តគ្នាក្នុងជួរតែមួយ (ដោយរថយន្តA ឈប់ពីមុខរថយន្តB) ដើម្បីចាំភ្លើងសញ្ញាពណ៌ខៀវ នៅចំណុចស្តុបមួយកន្លែង ។ ស្រាប់តែពេលនោះមានរថយន្ត Cមួយគ្រឿងទៀតបើកមកបុកពីក្រោយរថយន្ត B និងបានធ្វើឱ្យរថយន្តBនោះជ្រុលទៅបុករថយន្តA ដែលនៅពីមុខ ធ្វើឱ្យរងការខូចខាត ។

ក្នុងករណីខាងលើនេះព្យសនកម្មបានកើតឡើងដោយមានរថយន្តចំនួន ០២គ្រឿងចូលរួមបង្កព្យសនកម្ម ប៉ុន្តែក្នុងករណីនេះរថយន្ត B គ្មានកំហុសក្នុងការធ្វើឱ្យកើតមានព្យសនកម្មនោះទេ ហើយរថយន្តដែលមានកំហុសធ្វើឱ្យមានព្យសនកម្មកើតឡើងគឺរថយន្ត C ។ ដូច្នេះ កម្មសិទ្ធិករនៃរថយន្ត B អាចរួចផុតពីការទទួលខុសត្រូវបាន ដោយគ្រាន់តែបង្ហាញភស្តុតាងថាព្យសនកម្មកើតឡើង គឺមិនមែនជាកំហុសខ្លួន ហើយព្យសនកម្មកើតឡើងដោយសារកំហុសនៃកម្មសិទ្ធិករនៃតថយន្ត C ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ ពុំមានបុគ្គលណាម្នាក់ចង់បង្កជម្លោះ និងធ្វើឱ្យមានការខូចខាតដល់អ្នកដទៃឡើយ ប៉ុន្តែវានៅតែអាចកើតឡើងបាន និងឈានទៅរកការទទួលខុសត្រូវបើទោះបីជាអំពើនោះមិនមែនជាកំហុសផ្ទាល់របស់ចារីក៏ដោយ ។ ជាក់ស្តែង ប្រធានបទមួយនេះជាការទទួលខុសត្រូវលើអំពើនីត្យានុកូលរបស់កម្មសិទ្ធិករចំពោះទ្រព្យសម្បត្តិរបស់ខ្លួន រួមមានសំណង់អគារ វត្ថុគ្រោះថ្នាក់ និងផលិតផលផ្សេងៗ។ ជាគោលការណ៍ កាលណាមានការសាងសង់សំណង់អគារកើតឡើងត្រូវតែមានគណកម្មការចុះត្រួតពិនិត្យនូវគុណភាពអគារដែលកំពុងសាងសង់ ជៀសវាងមានការសាងសង់អគារគ្មានគុណភាព និង គ្មានការអនុញ្ញាតត្រឹមត្រូវ។ រីឯចំពោះបញ្ហាគ្រោះថ្នាក់ចរាចរណ៍វិញគឺនៅតែកើតមានឡើងជារឿយៗ ដោយសារតែខ្វះការត្រួតពិនិត្យពីក្រសួងសាធារណការ និង ដឹកជញ្ជូន ដោយមិនបានត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសអំពីការបំពាក់ភ្លើងបំភ្លឺនៅតាមដងផ្លូវដែលមនុស្សធ្វើដំណើរច្រើនដូចជានៅតាមទីក្រុងជាដើម ដែលសុទ្ធតែជាបញ្ហាបង្កឱ្យមានគ្រោះថ្នាក់។ មួយវិញទៀត ផលិតផលដែលដាក់លក់នៅលើទីផ្សារដោយគ្មានការចុះបញ្ជីត្រឹមត្រូវ ក្រសួងសុខភិបាល និងក្រសួងពាណិជ្ជកម្មក៏គួរតែចាត់វិធានការចុះត្រួតពិនិត្យតេស្តស្វែងរកផលិតផលណាដែលដាក់លក់នៅលើទីផ្សារគ្មានគុណភាព ដើម្បីជៀសវាងការបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផលិតផលនោះ។

សរុបសេចក្តីមក ការទទួលខុសត្រូវលើអំពើនៃវត្ថុគ្មានវិញ្ញាណ គឺជាផ្នែកមួយនៃការទទួលខុសត្រូវអំពើអនីត្យានុកូល ដែលជាការទទួលខុសត្រូវលើអគារដែលសាងសង់គ្មានការអនុញ្ញាតត្រឹមត្រូវពីគណកម្មការចុះត្រួតពិនិត្យសំណង់អគារ ការទទួលខុសត្រូវទៅលើបញ្ហាចរាចរណ៍ដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និង ដឹកនាំដោយក្រសួងសាធារណការនិងដឹកជញ្ជូន ការទទួលខុសត្រូវលើផលិតផលដែលដាក់លក់ ឬដាក់ឱ្យប្រើប្រាស់នៅលើទីផ្សារ គួរតែឆ្លងកាត់ការត្រួតពិនិត្យពីក្រសួងសុខាភិបាល និងក្រសួងពាណិជ្ជកម្មជាមុនសិនទើបមិនបណ្តាលឱ្យមានផលប៉ះពាល់ក៏ដូចជាគ្រោះថ្នាក់ដល់សុខភាព ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សា ស្រាវជ្រាវកន្លងមកយើងសង្កេតឃើញថា ច្បាប់បានកំណត់យ៉ាងច្បាស់លាស់ពីការទទួលខុសត្រូវរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងវត្ថុ លើអំពើនៃវត្ថុរបស់ខ្លួន ដោយចែងឱ្យមានការជួសជុលព្យសនកម្មដែលបានកើតឡើងលើជនរងគ្រោះ ដោយការជុសជុលព្យសកម្មគឺត្រូវធ្វើឡើងតាមទំហំនៃការខូចខាតដែលបានកើតឡើង ។ ទោះបីជាមានច្បាប់បានចែងពីការទទួលខុសត្រូវលើអំពើនៃវត្ថុក៏ដោយ ក៏យើងសង្កេតឃើញមានការខូចខាតដែលបង្កឡើងដោយអំពើនៃវត្ថុ ដោយសារការខ្វះការយល់ដឹង ការធ្វេសប្រហែស ខ្ជីខ្ជា ខ្វះការប្រុងប្រយ័ត្ន និងមិនមានការយោគយល់អាធ្យាស្រ័យគ្នា ជាពិសេសបញ្ហាទាក់ទងទៅនឹងសំណង់អគារ ការនាំចូលនូវផលិតផលផ្សេងៗដែលគ្មានស្តង់ដាដែលអាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាព និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីអំពើនៃវត្ថុ ។ បចុប្បន្នករណីទាក់ទងនឹងសំណង់អគារ ការនាំចូលផលិតផលគ្មានស្តង់ដា និងគ្រោះថ្នាក់ចរាចរណ៍ គឺឃើញថាមានកើតឡើងច្រើន នៅក្នុងប្រទេសកម្ពុជារបស់យើង។

ករណីដែលបានរៀបរាប់ខាងលើនេះ គឺជាបញ្ហាកង្វល់មួយរបស់សង្គម ដោយហេតុថានេះគឺជាបញ្ហាដែលទាក់ទងនឹង សណ្តាប់ធ្នាប់ របៀបរៀបរយ និងសេដ្ឋកិច្ចរបស់ប្រទេស ។ ដូចនេះ ដើម្បីដោះស្រាយបញ្ហាទាំងនេះ យើងសូមអនុញ្ញាតបញ្ចេញនូវមតិដូចខាងក្រោម៖

- ស្នើសុំឱ្យមានការបង្កើតនូវគណៈកម្មការដោះស្រាយវិវាទលើករណីសំណង់អគារ និង គណៈកម្មការចុះត្រួតពិនិត្យគុណភាពអគារដែលកំពុងសាងសង់ ជៀសវាងមានការសាងសង់អគារគ្មានគុណភាពនិងគ្មានការអនុញ្ញាតត្រឹមត្រូវ។
- ស្នើសុំឱ្យក្រសួងសាធារណការនិងដឹកជញ្ជូនបំពាក់ស្លាកសញ្ញាចរាចរណ៍គ្រប់ទីកន្លែង ជាពិសេសនៅតាមដងផ្លូវដែលមានមនុស្សធ្វើដំណើរច្រើន ផ្លូវបត់ ផ្លូវកែង និងផ្លូវបំបែកជាបួនជាដើម ព្រមទាំងធ្វើការបំពាក់ភ្លើងបំភ្លឺផ្លូវនៅតាមផ្លូវបេតុង និងផ្លូវលំតូចៗបន្ថែមទៀត។
- ស្នើសុំឱ្យក្រសួងសុខាភិបាលនិងក្រសួងពាណិជ្ជកម្មពង្រឹងនូវការចុះត្រួតពិនិត្យរាល់ផលិតផលដែលដាក់លក់នៅលើទៅផ្សារឱ្យមានការចុះបញ្ជីត្រឹមត្រូវ ហើយចេញវិធានការដើម្បីធ្វើការតេស្តរកគុណភាពរបស់ផលិតផលដើម្បីធ្វើឱ្យប្រជាពលរដ្ឋមានភាពជឿជាក់លើផលិតផលដែលបានប្រើប្រាស់។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

### ១.១. លិខិតបទដ្ឋានគតិយុត្តជាតិ

**ក.ច្បាប់ធរមាន**

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងវិសោធនកម្ម លេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧
- ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ លេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ លេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦
- ប្រកាស ស្តីពីការគ្រប់គ្រងបំណុលពន្ធដា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០

**ខ.ច្បាប់និរាករណ៍**

- ច្បាប់ភូមិបាល ឆ្នាំ២០០១
- ច្បាប់ភូមិបាល ឆ្នាំ១៩៩២

### ១.២. លិខិតបទដ្ឋានគតិយុត្តបរទេស

- ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ រៀបរៀងដោយ ក្រុមការងារនៃគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- សេចក្តីកំណត់ក្រមរដ្ឋប្បវេណី ភាគ៣ រៀបចំដោយ គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី
- សន្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១
- សន្ទានុក្រមច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩
- ញឹក វុធ្ធី នីតិកាតព្វកិច្ច ភាគ២ សរុបចំនួន ៤៥ទំព័រ

- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧ សរុបចំនួន ៥៣៤ទំព័រ
- បណ្ឌិត ហាប់ ផល្មី នីតិរដ្ឋប្បវេណី ភ្នំពេញ ឆ្នាំ២០១១ សរុបចំនួន ៩៦ទំព័រ
- សួស ចំរើន គ្រប់គ្រងសំណង់ ឆ្នាំ២០០៣ សុរុបចំនួន ១៨៩ទំព័រ

## ៣. ឯកសារយោងជាគេហទំព័រ

- Thmeythmey "បាក់អគារនៅកែបៈ នាយករដ្ឋមន្ត្រីប្រកាសថា អ្នកមានកំហុស បានស្លាប់" ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ គេហទំព័រ៖ https://thmeythmey.com/m/?page=detail&id=86822 ថ្ងៃចូលគេហទំព័រ ០១ ឧសភា ឆ្នាំ២០២៣
- Dap-new "ផ្តន្ទាទោស នាយិកាក្រុមហ៊ុន Nutrilatt Master LM Co.LTD ដាក់គុក១០ខែ និងបង្គាប់ឱ្យសងប្រាក់ជិត ៤០ម៉ឺនដុល្លារ ពាក់ព័ន្ធលក់ម្សៅទឹកដោះគោគ្មានគុណភាព និងប៉ះពាល់សុខភាពទារក និងកុមារនៅកម្ពុជា" ផ្សាយដោយ DR103 ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ គេហទំព័រ https://dap-news.com/national/2022/04/03/233995/ ថ្ងៃចូលគេហទំព័រ ០១ ឧសភា ឆ្នាំ២០២៣
- Nop Kanharith "ប្រធានសក្តិ" គេហទំព័រ៖ https://nopkanharith.com/2022/06/21/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%92%E1%9E%B6%E1%9E%93%E1%9E%9F%E1%9E%80%E1%9F%92%E1%9E%8F%E1%9E%B7/ ថ្ងៃចូលគេហទំព័រ ១០ ឧសភា ឆ្នាំ២០២៣

## ៤.ឯកសារយោងផ្សេងៗ

- ឯកឧត្តម ហ៊ី សោភា មេរៀនស្តីពីអំពើអនីត្យានុកូល
- សេចក្តីប្រកាសព័ត៌មានរបស់នាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក។ប.ប" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ "បណ្តឹងឪពុកម្តាយ ១៥គ្រួសារ លើក្រុមហ៊ុនទឹកដោះគោ Nutrilatt"

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី២** ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី៣** ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី៤**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងវិសោធនកម្ម លេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៥** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ លេខ នស/រគម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី៦** ច្បាប់ស្តីពីការគ្រប់គ្រងឱសថ លេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦

**ឧបសម្ព័ន្ធទី៧** ច្បាប់ភូមិបាល ឆ្នាំ២០០១

**ឧបសម្ព័ន្ធទី៨** ច្បាប់ភូមិបាល ឆ្នាំ១៩៩២

**ឧបសម្ព័ន្ធទី៩** ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤

# ឧបសម្ព័ន្ធទី១

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## មាតិកាទី ១

## ច្បាប់ព្រហ្មទណ្ឌ

### ជំពូកទី ១

### គោលការណ៍ទូទៅ

**មាត្រា ១.– ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ**

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងរបៀបនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.– និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស**

ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ នៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.– គោលការណ៍នីត្យានុកូលភាព**

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.– ចេតនាប្រព្រឹត្តបទល្មើស**

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសក៏អាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការ[illegible] ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។



Kol

# ឧបសម្ព័ន្ធទី២

## គន្ថីទី ១
## បទប្បញ្ញត្តិទូទៅ
## ជំពូកតែមួយ
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

**មាត្រា ២.-** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.-** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

**មាត្រា ៤.-** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

**មាត្រា ៥.-** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

# គន្ថីទី ៣

# សិទ្ធិប្រត្យក្ស

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១

### វត្ថុ

**មាត្រា ១១៩.-** និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

**មាត្រា ១២០.-** ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

**មាត្រា ១២១.-** សមាសភាគនៃវត្ថុ

ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបំបែកចេញបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

**មាត្រា ៧៤៨.–** អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

**មាត្រា ៧៤៩.–** អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

**មាត្រា ៧៥០.–** ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

**មាត្រា ៧៥១.–** ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

**មាត្រា ៧៥២.–** ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់បើកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧក្សាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

**មាត្រា ៧៥៣.–** ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

**មាត្រា ៧៥៤.–** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.–** និយមន័យនៃការការពារជាពម្មានរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាពម្មានរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.–** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

យល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះមិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

**មាត្រា ៧៥៧.–** គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

**មាត្រា ៧៥៨.–** ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់ទូវស្ថិតិ និងឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើ

អនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

**មាត្រា ៧៥៩.–** ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

**មាត្រា ៧៦០.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្ដល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវត្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវត្រឹត្តិដែលបុគ្គលដែលទទួលជីវត្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅ

ក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណង នៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

**មាត្រា ៧៦១.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

**មាត្រា ៧៦២.–** ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

**មាត្រា ៧៦៣.–** ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៤.–** ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬវិតរាលដាលនៃការខូចខាត តុលាការ

អាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៥.-** អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។

# ឧបសម្ព័ន្ធទី៣

## មាតិកាទី ៣
## បណ្តឹងរដ្ឋប្បវេណី
## ជំពូកទោល
## បណ្តឹងរដ្ឋប្បវេណី

**មាត្រា ១៣.** – បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម

បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។

ដើម្បីឲ្យទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ :

-ជាផលវិបាកផ្ទាល់នៃបទល្មើស

-ជាព្យសនកម្មផ្ទាល់ខ្លួន

-បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ។

ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត ។

**មាត្រា ១៤.** – ការជួសជុលព្យសនកម្ម

ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឲ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាត ។

សំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈពួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង ។

**មាត្រា ១៥.** – ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន កាលណាជនរងគ្រោះនេះជាអនីតិជន ឬជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ ។

**មាត្រា ១៦.** – បណ្តឹងរដ្ឋប្បវេណីរបស់សិទ្ធិវន្តនៃជនរងគ្រោះ

ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬបន្តបាន ដោយសិទ្ធិវន្ត ។

**មាត្រា ១៧.** – សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី ៣ (បី) ឆ្នាំ មុនកាល

# ឧបសម្ព័ន្ធទី៤

ម្ចាស់យានជំនិះត្រូវទទួលខុសត្រូវបង់សោហ៊ុយថ្លៃស្តូច និងថ្លៃរក្សាទុកបន្ថែមលើប្រាក់ពិន័យ។

សោហ៊ុយថ្លៃស្តូចនិងថ្លៃរក្សាទុក ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៨ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ដែលមានសមត្ថកិច្ចត្រួតពិនិត្យបទល្មើសចរាចរណ៍ ត្រូវពិនិត្យ អង្កេត កត់ត្រាបទល្មើសស្របតាមបែបបទនៃការពិនិត្យ ការអង្កេត ការកត់ត្រាបទល្មើស និងការធ្វើកំណត់ ហេតុគ្រោះថ្នាក់ចរាចរណ៍ដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា៦៩ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ដែលមានសមត្ថកិច្ចផាកពិន័យបទល្មើសចរាចរណ៍ ត្រូវចេញ បង្កាន់ដៃផាកពិន័យដែលមានគល់បញ្ជីត្រឹមត្រូវ។ ទម្រង់បែបបទនៃបង្កាន់ដៃផាកពិន័យនិងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការផាកពិន័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៧០ ..**

បុគ្គល ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីអនុវត្តច្បាប់ដូចមានចែងក្នុងមាត្រា៦០នៃច្បាប់នេះ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីនោះ។ ប្រធានអង្គភាពត្រូវ សម្រេចលើបណ្តឹងតវ៉ា១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹង។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តី សម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធី។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា៧១ ..**

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧២ ..**

អ្នកបើកបរ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងការបើកបរយានជំនិះ។

អ្នកគ្រប់គ្រងឬកម្មសិទ្ធិករ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងករណីយានជំនិះរបស់ខ្លួនបានបង្កឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ។

**មាត្រា៧៣ ..**

ការរំលោភបំពានលើរាងកាយ កិត្តិយស សេចក្តីថ្លៃថ្នូរ របស់មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

# ឧបសម្ព័ន្ធទី៥

**មាត្រា ១០.– ថ្មី**

១-ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល (មួយលានរៀល) ដល់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ចំពោះជនណាដែលបាន :

-ផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសំអាងតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌក្នុងការគ្រប់គ្រងថែរក្សាផលិតផលឱសថ

-បើក បិទ ឬ ប្ដូរទីតាំងឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានលក់គ្រឿងសំអាង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

២-ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ចំពោះជនណាដែលបាន :

-បើក បិទ ឬ ប្ដូរទីតាំងគ្រឹះស្ថានលក់ដុំឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថ គ្រឹះស្ថាននាំចូល នាំចេញឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម អាហរ័ណ នីហរ័ណឱសថ

-នាំចូល ឬ នាំចេញ ផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ចែកចាយ តាំងលក់ ឬ លក់ផលិតផលឱសថ និងគ្រឿងសំអាងដែលគ្មានចុះលេខទិដ្ឋាការ ឬ បញ្ជិកាពីក្រសួងសុខាភិបាល

-លក់ឱសថខូចគុណភាព និងឱសថផុតកំណត់ប្រើប្រាស់ ។

៣-ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ចំពោះជនណាដែលបាន :

-បើក បិទ ឬ ប្ដូរទីតាំងគ្រឹះស្ថានផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសផលិតឱសថ

-នាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច សម្ភារៈវេចខ្ចប់ម៉ាស៊ីនឧបករណ៍សម្រាប់ផលិតឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ផលិតឱសថដែលមានគុណភាព មិនត្រឹមត្រូវតាមស្តង់ដារគុណភាពក្នុងឯកសារសុំទិដ្ឋាការឱសថ

-ស្តុកវត្ថុធាតុដើម សម្ភារៈវេចខ្ចប់ ម៉ាស៊ីនឧបករណ៍ផលិត ផលិតផលឱសថក្រៅពីគ្រឹះស្ថានអាជីវកម្ម ផលិតកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៤-ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬ អាយុជីវិតមនុស្ស សត្វ ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អា-ហារ៍ណ នីហរ៍ណ និងពាណិជ្ជកម្មឱសថជាបន្ទាន់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

៥-ទោសទណ្ឌទាំងឡាយណា ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ក្រសួងសុខាភិបាលមានសិទ្ធិពិន័យអន្តរការណ៍ ។

ក្នុងករណីវិវាទ្យសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងសុខាភិបាលត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១១.- ថ្មី**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ខែ ឬ ផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ រៀល (ពីរលានរៀល) ដល់ ១០.០០០.០០០រៀល (ដប់លានរៀល) ឬ ទោសទាំងពីរ ចំពោះជនណាដែលរារាំងប្រឆាំងនឹងការអនុវត្តច្បាប់នេះ ។

**មាត្រា ១២.- ថ្មី**

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ដល់ ៥០.០០០.០០០ រៀល (ហាសិបលានរៀល) ចំពោះជនណាដែលបាន :

-ផលិត នាំចូល ឬ ស្តុកឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ សារធាតុញៀន សារធាតុផ្សំគ្រឿងញៀន ដែលកំណត់ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឬ

# ឧបសម្ព័ន្ធទី៦

# ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅគ្រប់គ្រងឱសថក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ឱសថគឺជាសារជាតិមួយមុខ ឬច្រើនមុខដែលមានប្រភេទជាអាទិ៍ពី ជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ រុក្ខជាតិ លាយផ្សំឡើងសម្រាប់ :

-ប្រើប្រាស់ក្នុងការបង្ការឬព្យាបាលជម្ងឺមនុស្ស សត្វ

-ការស្រាវជ្រាវវេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ

-កែប្រែឬទ្រទ្រង់មុខងារនៃសរីរាង្គ ។

មាត្រា ៣.-

ត្រូវបានចាត់ទុកជាឱសថដែរ :

១-សេរ៉ូម ឬវ៉ាក់សាំង

២-ឈាម ឬផលិតផលដែលបានមកពីឈាម

៣-ឱសថបុរាណ

៤-ផលិតផលដែលផ្សំឡើងដោយមានជាតិពុល ដែលមានក្នុងបញ្ជីកំណត់ដោយអនុក្រឹត្យ។

មាត្រា ៤.-

អាចមានសិទ្ធិធ្វើផលិតកម្ម អាហរ័ណនីហរ័ណកម្ម និងពាណិជ្ជកម្មឱសថបាន ចំពោះឱសថការីដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ :

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រជាឱសថការីទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ចំពោះការផលិត អាហរ័ណនីហរ័ណកម្ម និងពាណិជ្ជកម្មឱសថបុរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២
## ការគ្រប់គ្រងជាតិពុលសម្រាប់វិស័យសុខាភិបាល

មាត្រា ៥.-

ជាតិពុលសំដៅលើឱសថ ឬសារជាតិ ឬសមាសធាតុនៃសារជាតិ ឬរុក្ខជាតិ ដែលអាចបង្កឱ្យគ្រោះថ្នាក់ដល់សុខភាព ឬឱ្យញៀនដល់មនុស្ស សត្វ ។

ជាតិពុលនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៦.-

បែបបទនិងលក្ខខណ្ឌក្នុងផលិតកម្ម អាហរណ៍ នីហរណកម្ម និងពាណិជ្ជកម្មជាតិពុល ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៣
## ផលិតកម្ម អាហរណ៍ នីហរណកម្ម និងពាណិជ្ជកម្មឱសថ

មាត្រា ៧.-

បែបបទនិងលក្ខខណ្ឌបច្ចេកទេសផលិតកម្មនិងការប្រព្រឹត្តទៅនៃគ្រឹះស្ថានផលិតឱសថ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាលនូវ :

-បែបបទនិងលក្ខខណ្ឌក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរណ៍នីហរណ៍ឱសថ

-បែបបទនិងលក្ខខណ្ឌក្នុងការសុំទិដ្ឋាការ បញ្ជីការឱសថ

-បែបបទនិងលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រងនិងថែរក្សាឱសថ

-បែបបទនិងលក្ខខណ្ឌក្នុងការផ្សព្វផ្សាយឱសថ

-ព្រមទាំងបែបបទផលិតកម្ម អាហរណ៍ នីហរណកម្ម និងពាណិជ្ជកម្មឱសថ ។

ការកំណត់ចំនួនគ្រឹះស្ថានលក់ឱសថត្រូវធ្វើឡើងដោយក្រសួងសុខាភិបាលដោយផ្អែកលើចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ ឃុំ ជាមូលដ្ឋាន ។

# ឧបសម្ព័ន្ធទី៧

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ចាត់ទុកជាអចលនវត្ថុ តាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនានិងអចលនវត្ថុតាមការកំណត់របស់ច្បាប់ ។

អចលនវត្ថុពីកំណើតមានដីធម្មជាតិដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរនិងសំណង់ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិលឬផ្លាស់ប្តូរកន្លែងបាន ។

អចលនវត្ថុពីភ័ព្វវាសនាមានវត្ថុដែលជាប់នឹងដីឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យមានការខូចខាតឬមិនផ្លូវសភាពដើមដូចជាដើមឈើ ឧបករណ៍តែងលំអជាដើម ។

អចលនវត្ថុតាមការកំណត់របស់ច្បាប់មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុនិងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ ។

**មាត្រា ៣.-**

ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋនិងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។

ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនិងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ។

បទបញ្ញាទិងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

# ឧបសម្ព័ន្ធទី៨

មានការផ្ដួចកម្មនៃមូលនិធិ ដូចជា៖ឧបករណ៍យន្ដការ , ឧបករណ៍សំរាប់ភ្ជួរ , សំរាប់រាស់ , សំរាប់ដឹកនាំ សំរាប់ប្រហារ , សំរាប់ស្ទូង , រនាស់ , នង្គ័ល , ឧបករណ៍ , ឧបករណ៍សិប្បកម្ម , ប្រដាប់ប្រដា និងសម្ភារៈទាំងឡាយ ដី ពូជ និងជីធម្មជាតិ ដែលកាលណាប្រើប្រាស់ទាំងនោះជារបស់ដែលជាប់ជាមួយនឹងអចលនវត្ថុពីកំណើត ដោយប្រការថា បើគេនឹងបំបែកវាចេញពីអចលនវត្ថុ ធ្វើឲ្យខាតបង់ផលតំរូវសេដ្ឋកិច្ច ហើយធ្វើឲ្យវាខូចខាតបង់ខ្លួនលើសពីតំលៃ ខូចប្រយោជន៍ ខូចលំអក្បាច់ និងខូចលំអនៃអចលនវត្ថុនោះ ដូចជាគ្រឿងព្រួញ ដូចជាង ចង្ក្រានទឹក កញ្ចក់ បដិមាករ និងរូបចម្លាក់ ឬ ភ្ជាប់នឹងជញ្ជាំង ពិដាន និងក្ដារក្រាលឥដ្ឋ ។

<u>មាត្រា ៩ :</u> អចលនវត្ថុតាមលក្ខណៈរបស់ច្បាប់ នោះគឺវត្ថុដែលច្បាប់កំណត់ឲ្យចាត់ទុកជា អចលនវត្ថុពីកំណើត ទោះបីវាជាវត្ថុមិនអាចនាំទៅបាន ។ អចលនវត្ថុទាំងឡាយនោះ គឺ កប៉ាល់ដែលមានចំណុះ ៣០ តោនឡើងទៅ ផ្ទះដែលសង់មានបំពង់ផ្សែង និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ ។

<u>មាត្រា ១០ :</u> ទ្រព្យជាអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះ ជួនកាលអាចជារបស់ឯកជនដែលជនតែម្នាក់ ឬ ច្រើននាក់ ដែលមានចំណែករៀងៗខ្លួនលើទ្រព្យតែមួយនោះ ឬ ដែលសិទ្ធិទាំងមូលនោះ ដែលនឹងធ្វើឲ្យបែកម្ចាស់ពុំបាន ជួនកាលជារបស់សមូហភាពនៃប្រជាជនមួយក្រុម ឬ ជារបស់ប្រជាជនទាំងអស់ក៏មាន ។

ទ្រព្យប្រភេទទី មួយ "ទ្រព្យឯកជន" ត្រូវចុះជាកម្មសិទ្ធិឯកជនផ្ទាល់ខ្លួនម្នាក់ៗ ទ្រព្យប្រភេទទី ពីរ "ទ្រព្យសមូហភាព" ត្រូវចុះជាសម្បត្តិសាធារណៈ និងជាសម្បត្តិឯកជននៃសមូហភាព ។

ក្នុងករណីទាំងឡាយនេះ ទោះជាឯកជនក្ដី សមូហភាពក្ដី ត្រូវតែមានសិទ្ធិលើអចលនវត្ថុដូចមានរាយរាប់ខាងក្រោមនេះ ឯសិទ្ធិក្រៅពីនោះ ច្បាប់មិនទទួលស្គាល់ទេ :-

១_កម្មសិទ្ធិ
២_ភោគៈ
៣_ការអនុញ្ញាតឲ្យដាំដុះ
៤_សម្បទាន
៥_ផលុបភោគ
៦_សិទ្ធិប្រើប្រាស់ និង អាស្រ័យនៅ
៧_ភេទភាព
៨_ការបញ្ចាំអចលនវត្ថុ
៩_អនុប្បទាន
សិទ្ធិដីការអនុញ្ញាតឲ្យដាំដុះ និងសិទ្ធិសម្បទាន នឹងកំណត់ក្នុងច្បាប់ដោយឡែក ។

<u>មាត្រា ១១ :</u> ផលុបភោគ សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ ភេទភាព ទាំងអស់នោះជាប្រការធ្វើឲ្យសៅហ្មងដល់សិទ្ធិរបស់កម្មសិទ្ធិករ ឲ្យបានអាស្រ័យផ្ដាច់មុខដែលម្នាក់ឯងនូវកម្មសិទ្ធិរបស់ខ្លួន ដោយខ្លួនក្រៅច្បាប់ ដោយព្រមព្រៀងគ្នាផង ឬ ដោយច្បាប់បង្ខំផង ។ សិទ្ធិទាំង ៣ ខាងលើនេះ មានចែងក្នុងមាតិកាទី III ស្ដីអំពីវត្ថុនៃកម្មសិទ្ធិ ដែលមិនមែនជាព្រាតិកាប្រត្យក្សទេ ។

ការបញ្ចាំអចលនវត្ថុ ចាត់ទុកជាគ្រឿងធានាប្រត្យក្សសំរាប់ការពារលោកម្ចាស់បំណុលដែលកម្មសិទ្ធិករបានដាក់អចលនវត្ថុជាគ្រឿងធានានោះ ឲ្យគេចែកទៅតាមលំដាប់ ដែលត្រូវតែប្រតិបត្តិតាមការព្វកិច្ចរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកទទួលបញ្ចាំ ។

<u>ផ្នែកទី ២</u>

អំពីចំនាត់ចំណែកថ្នាក់អចលនវត្ថុតាមរូបម្ចាស់អចលនវត្ថុ

<u>មាត្រា ១២ :</u> ម្ចាស់អចលនវត្ថុដែលច្បាប់ទទួលស្គាល់ មានសិទ្ធិទទួលផលគ្រប់បែបយ៉ាង អំពីអចលនវត្ថុនោះ មានផលកម្មជាតិ និងផលស៊ីវិល ។

# ឧបសម្ព័ន្ធទី៩

nécessaires et utiles qui ont été faites pour la conservation de la chose.

## CHAPITRE II.

### *DES DÉLITS ET DES QUASI-DÉLITS.*

#### 1382.

Tout fait quelconque de l'homme, qui cause à autrui un dommage, oblige celui par la faute duquel il est arrivé, à le réparer.

#### 1383.

Chacun est responsable du dommage qu'il a causé non-seulement par son fait, mais encore par sa négligence ou par son imprudence.

#### 1384.

On est responsable non-seulement du dommage que l'on cause par son propre fait, mais encore de celui qui est causé par le fait des personnes dont on doit répondre, ou des choses que l'on a sous sa garde.

Le père, et la mère après le décès du mari, sont responsables du dommage causé par leurs enfans mineurs habitant avec eux;

Les maîtres et les commettans, du dommage causé par leurs domestiques et préposés dans les fonctions auxquelles ils les ont employés;

Les instituteurs et les artisans, du dommage causé par leurs élèves et apprentis pendant le temps qu'ils sont sous leur surveillance.

La responsabilité ci-dessus a lieu, à moins que les père

et